# កូនមាសឪពុក



រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

សម្រាប់ជាធម្មទាន

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនត្រូវហាត់ធ្វើខ្លួនឱ្យសុភាពរាបសា មានការព្យា-យាម ចេះអើពើជួយធ្វើការអ្នកដទៃដោយសេចក្តីពេញចិត្ត និងធ្វើខ្លួនឱ្យជាមនុស្សបានការ ដើម្បីជាប់ជាឧបនិស្ស័យដល់ធំឡើងកូនបានធ្វើជាមនុស្សល្អ ជាមនុស្សមានសេចក្តីចម្រើនមាំទាំក្នុងជីវិត ។

កូននៅតូច កូនធ្វើអ្វីត្រូវឱ្យនៅក្នុងការហ្វឹកហាត់កសាងខ្លួន បើកូនមានស្មារតីកសាងខ្លួនជានិច្ចនោះ កូនធ្វើអ្វីៗតែងមានរបៀបរៀបរយ កាលបើមានរបៀបរៀប-រយល្អហើយ កូនអាចរៀនសូត្រនិងធ្វើការងារផ្សេងៗបានដោយត្រឹមត្រូវ តទៅកូននឹងបានជាមនុស្សមាននូវសេចក្តីសម្រេច និងសេចក្តីចម្រើនឱ្យដល់ខ្លួនឯងព្រមទាំងសង្គមគ្រួសារសង្គមជាតិក្នុងអនាគតយ៉ាងពិតប្រាកដ ។

-១-

## កូនមាសឪពុក

កូនត្រូវតែជាមនុស្សល្អដូចតទៅ :

១-ជាកូនដែលល្អរបស់ឪពុកម្តាយ
២-ជាសិស្សដែលល្អរបស់គ្រូអាចារ្យ
៣-ជាមិត្តដែលល្អរបស់មិត្ត
៤-ជាប្រជាពលរដ្ឋល្អរបស់ប្រទេសជាតិ
៥-ជាសាវ័កល្អរបស់ព្រះសម្មាសម្ពុទ្ធ ។

ចូរកូនមានជីវិតត្រឹមត្រូវនៅក្នុងលោកនេះ ដោយខំប្រឹងសាងនូវសុចរិតពិតប្រាកដ ចូរកូនរស់នៅឱ្យបានជាក្តីសង្ឃឹមរបស់មនុស្សទាំងឡាយ ចូរកូនប្រាថ្នាឱ្យពិភពលោកបានជួបនូវសេចក្តីសុខស្ងប់ ។

-២-

Document Produced by deskPDF Unregistered :: http://www.docudesk.com



កូនត្រូវដឹងថា : ធម៌រមែងរក្សាឱ្យយើងមានសេចក្ដីសុខ តែធម៌នឹងមករក្សាយើងមិនបានឡើយ បើយើងមិនចូលទៅរកធម៌ទេនោះ ប្រៀបដូចជាអាហារ នឹងមកឱ្យយើងឆ្អែតមិនបានដោយពិត បើយើងមិនទៅបរិភោគនូវអាហារនោះៗទេ យ៉ាងណាមិញ ធម៌ក៏យ៉ាងនោះដែរ បើយើងមិនយកមកបដិបត្តិទេ ធម៌ក៏ជួយអ្វីយើងមិនបានឡើយ ដូច្នេះ ក្នុងការដែលយើងនឹងមាននូវសេចក្ដីសុខសេចក្ដីចម្រើនទៅបាននោះ ក៏ព្រោះតែយើងបានបដិបត្តិនូវធម៌ហ្នឹងឯង ។

ធម៌ជារបស់ចាំបាច់ក្រៃលែងជាងអាហារ ក្រៃលែងជាងខ្យល់អាកាស និងក្រៃលែងជាងអ្វីៗទាំងអស់ ព្រោះធម៌ធ្វើឱ្យជីវិតយើងមានគុណតម្លៃ ។





ជីវិតរបស់ឪពុកតាំងពីមានកូនរហូតមកដល់ខណៈនេះ សេចក្ដីប្រាថ្នារបស់ឪពុកដែលមានចំពោះកូនគឺ សូមឱ្យកូនមានការចេះដឹងល្អ និងមានការប្រព្រឹត្ត ល្អ ។

ទ្រព្យសម្បត្តិមិនមែនជារបស់សំខាន់ខ្លាំងណាស់ទេក្នុងការដែលឪពុកម្ដាយចែកឱ្យកូននោះ តែការចេះដឹងល្អនិងការប្រព្រឹត្តល្អ ជាសម្បត្តិសំខាន់ដ៏ក្រៃលែងដែលឪពុកនិងម្ដាយប្រាថ្នាប្រគល់ឱ្យដល់កូនជាទីស្រឡាញ់ និងជាទីហួងហែងរហូតមក ។

បើកូនធ្វើតាមពាក្យដែលឪពុកនិងម្ដាយណែនាំ ផលនឹងកើតបានជាគុណតម្លៃ និងជាសេចក្ដីសុខឱ្យដល់កូនរួមទាំងគ្រួសារព្រមទាំងអ្នកដែលនៅជុំវិញកូនទៀតផង ។

## កូនមាសឪពុក

ការចូលរៀនក្នុងសាលា ការលេងកីឡា ការសម្ដែងសិល្បៈជាដើមទាំងអស់នេះ គឺត្រូវមានគ្រូ មានការគ្រប់គ្រង មានការបង្វឹកពីខាងដើមមក យ៉ាងណាមិញ មនុស្សយើងតាំងពីតូចមករហូតដល់ធំ និងចេះមានការទទួលខុសត្រូវដោយខ្លួនឯងបាននោះ ក៏ត្រូវមានឪពុកមានម្ដាយ មានគ្រូ មានអ្នកមើលថែ និងមានអ្នកបង្វឹកបង្ហាត់បង្រៀន យ៉ាងនោះដែរ កាលបើកូនមានការចេះដឹងល្អ មានការប្រព្រឹត្តល្អហើយនោះ កូនរមែងមានសេចក្ដីសុខក្នុងជីវិតរបស់កូនយ៉ាងពិតប្រាកដ ។

ឪពុកនិងម្ដាយរបស់កូនមានសេចក្ដីសុខណាស់ កាលបើបានមើលថែនិងទូន្មានអប់រំដល់កូនហើយ កូនជាមនុស្សប្រដៅងាយ ប្រព្រឹត្តល្អចម្រើនដោយគុណ និងមានសីលធម៌ប្រចាំខ្លួនជាប់ជាឧបនិស្ស័យ តាមការដែលម៉ែឪទូន្មាននោះ ...ឪសូមឱ្យពរ ។



## កូនមាសឪពុក

កតញ្ញូតាធម៌ ជាគុណធម៌ដែលសំខាន់ក្នុងភាពជាមនុស្ស ។

ការដឹងគុណ និងការតបគុណនោះ អាចគ្រប់គ្រងរក្សាឱ្យកូនផុតអំពីភាពអាក្រក់ទាំងពួងបាន ។

បុគ្គលដែលតបគុណដល់អ្នកដែលមានគុណ រមែងមិននិយាយ មិនធ្វើ នូវអ្វីដែលជាហេតុឱ្យអ្នកមានគុណក្ដៅក្រហាយចិត្តឡើយ ។

កតញ្ញូតាធម៌មានកម្លាំងដ៏ក្រៃលែង បើមិនគិតឱ្យល្អទេ គឺមិនអាចយល់បានឡើយ ដូច្នេះ កតញ្ញូតាធម៌ត្រូវកូនខំប្រឹងគិតឱ្យបានល្អ កុំយល់ថាមិនសូវសំខាន់នោះ មនុស្សដែលអាក្រក់ ខុសសីលខុសធម៌ ខុសវិន័យទៅបាន តាំងតែពីខុសតូចរហូតដល់ខុសធំ គឺកើតមកអំពីការមិនដឹងគុណហ្នឹងឯង តែបើកូនជាមនុស្សចេះដឹងគុណ កូនមានតែសេចក្ដីចម្រើនដោយកុសល ម្យ៉ាងទៀត កតញ្ញូតាធម៌



Document Produced by deskPDF Unregistered :: http://www.docudesk.com

ដែលមានក្នុងខ្លួនកូនជាគ្រឿងសំគាល់ថា កូនមាសឪពុក ជាមនុស្សល្អ ។

កតញ្ញូតាការដឹងគុណ ជាទុនជីវិតពិតដ៏ផ្ទើម
ជួយញ៉ាំងបារមីធំសម្បើម និងជាដង្កើមនៃកុសល ។
កតញ្ញូតាការដឹងគុណ នាំចាកទារុណបាបកង្វល់
គឺជាបញ្ញាគ្រឿងតម្កល់ នាំខ្លួនចូលដល់កុសលកម្ម។
គុណធម៌ល្អណាស់ក្នុងខ្លួនមនុស្ស កូនកុំប្រទូស្តត្រូវចងចាំ
ជាធម្មតាគុណគ្មានប្រេះស្រាំ ទោះយូរខែឆ្នាំនៅតែល្អ ។
បើកូនចង់បានជាមនុស្សពិត ត្រូវមានគំនិតថ្លៃបវរ
កូនកុំយកខ្មៅធ្វើជា ស កុំយកគុណល្អមកជាន់ឈ្លី។

✍📖✍



# កូនមាសឪពុក

កូនត្រូវចាំទុក :

១-មាតាបិតាជាព្រះព្រហ្មរបស់បុត្រធីតា ការដែលធ្វើឱ្យមាតាបិតាលំបាកចិត្ត តឹងណែនក្នុងទ្រូង យំបង្ហូរទឹកភ្នែក គឺជាបាបកម្មដ៏ធ្ងន់របស់កូន ។

២-ការជឿស្តាប់ដំបូន្មានល្អរបស់មាតាបិតា រមែងមិនមានការសាបសូន្យឡើយ ពោលគឺមិនចចេសរឹងរូសតែម្យ៉ាង កូននឹងបានល្អគ្រប់យ៉ាង ។

៣-ការតបស្នងព្រះគុណដល់អ្នកមានគុណ គឺតាំងតែពីអ្នកមានគុណនៅមានជីវិតរហូតដល់ចែកឋាន ។

៤-ការបំពេញតួនាទីជាកូនល្អ គឺជាការបដិបត្តិធម៌ កូនល្អត្រូវភ្ញាក់ខ្លួន ត្រូវរហ័សរហួនរៀសរវៃ ត្រូវឈានទៅមុខ ត្រូវធ្វើការងារប្រជែងជាមួយពេលវេលា ដើម្បីកសាងខ្លួន និងដើម្បីការរីកចម្រើនដល់សង្គមជាតិ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

៥-អបាយមុខ គ្រឿងញៀន ជាផ្លូវនៃសេចក្តីវិនាស សម្រាប់ជីវិត កូនមាសឪពុកត្រូវដើរតាមផ្លូវព្រះ កុំដើរតាមផ្លូវរបស់មារ ការងារសុចរិតជាការងារថ្លៃថ្នូរមានកិត្តិយស កូនត្រូវចេះពិចារណាដោយខ្លួនឯង ដាស់តឿនខ្លួនឯង កុំឡេះឡោះ កុំទម្រន់ ត្រូវឆ្ងាយពីអបាយមុខ (ស្រី ស្រា ល្បែង និងបាបមិត្ត ) ត្រូវដើរនៅក្នុងផ្លូវធម៌ជានិច្ច។

កូនកុំប្រមាទក្នុងជីវិត ផ្លូវនេះនៅជិតក្បែរមាត់ជ្រោះ
ចិញ្ចឹមជីវិតឱ្យបានរស់ កូនត្រូវស្គាល់គ្រោះឱ្យជាក់លាក់។
បាបមិត្តស្រីស្រានិងល្បែងភ្នាល់ ព្រមទាំងមិនខ្វល់នឹងធុរៈ
ជាជ្រោះគ្រោះថ្នាក់ប្រាកដជាក់ ជ្រោះជ្រៅមិនរាក់ធ្លាក់បាក់ក។
ដំណើរជីវិតពិតលំបាក តែបានធូរស្រាកព្រោះធ្វើល្អ
ផ្លូវអបាយមុខមិនត្រាច់ចរ ចេះភ័យខ្លាចក្រប្រឹងរៀនសូត្រ។



# កូនមាសឪពុក

ពេលវេលាដែលកន្លងទៅ និងជីវិតឪដែលបានកន្លងមកនេះ ជារយៈពេលយូរដែរហើយ ជីវិតឪបានឆ្លងកាត់រឿងរ៉ាវនៃជីវិត ឆ្លងកាត់ព្យុះភ្លៀងនៃបញ្ហារាប់មិនអស់ ឆ្លងកាត់សុខទុក្ខ និងឆ្លងកាត់លោកធម៌ផ្សេងៗទៀតដ៏ច្រើនសន្ធឹកសន្ធាប់ ។

កូនស្ងួនមាសឪពុកអើយ ជីវិតរបស់មនុស្សគ្រប់រូបគ្រប់នាម មិនថាមានក្រល្អអាក្រក់ឡើយ ជាទីបំផុតនៃជីវិតទាំងអស់ ត្រូវធ្លាក់ចុះចូលក្នុងការចាស់ ការឈឺ និងសេចក្តីស្លាប់ជាពិតប្រាកដ ។

ក្នុងរយៈពេលនៃជីវិតឪដែលបានកន្លងមកនេះ ឪបានជួបប្រសព្វ និងបានដឹងរឿងរ៉ាវច្រើនក្នុងលោក ឪមានពាក្យដែលត្រូវប្រាប់កូនឱ្យបានដឹង ចូរកូនប្រុងចាំស្តាប់ :

ជីវិតមនុស្សយើងនឹងមានសេចក្តីសុខទៅបានទាល់តែយកធម៌មកជាកល្យាណមិត្ត យកធម៌មកទំនុកបម្រុងឱ្យ

ដល់ចិត្ត តាំងទុកក្នុងចិត្តជានិច្ចអចិន្ត្រៃយ៍ ។

ធម៌ក្នុងទីនេះគឺការបំពេញនូវមុខនាទី និងភាពត្រឹមត្រូវ ។

ក្នុងពេលខ្លះ សេចក្ដីទុក្ខក៏បានមកដល់ជីវិតដើម្បីសាកល្បងយើង បើយើងមានសេចក្ដីអត់ធន់ច្រើនប៉ុនណា សេចក្ដីសម្រេចក៏នឹងមានច្រើនប៉ុណ្ណោះដែរ ។ សេចក្ដីសម្រេច មានសម្រាប់អ្នកដែលមាននូវសេចក្ដីអត់ធន់ និងមាននូវសេចក្ដីព្យាយាម ។

សូមឱ្យកូនប្រកាន់នូវគតិមួយថា ឧបសគ្គរមែងមកមុនសេចក្ដីសម្រេច និងសូមកូននឹករឿយៗថា សេចក្ដីសុខឬសេចក្ដីទុក្ខ កើតឡើងពីការធ្វើរបស់យើងទាំងអស់ ។

ឪពុកសូមឱ្យកូនធ្វើតែអំពើល្អ ដល់ពេលជិតស្លាប់ចិត្តរបស់កូនមិនមានទុក្ខ មិនមានសៅហ្មងឡើយ ព្រោះការគិតរបស់មនុស្សជិតស្លាប់ កាលបើបាបច្រើន ការគិតក៏នាំយកសេចក្ដីក្ដៅក្រហាយមកដុតរោលចិត្ត តែបើធ្វើល្អ



ច្រើន ការគិតក៏នាំយកសេចក្ដីរីករាយមកប្រោះព្រំឱ្យចិត្តត្បិតឃើញនូវអំពើដ៏បរិសុទ្ធរបស់ខ្លួន ។

អ្នកធ្វើល្អ រស់នៅក៏បានល្អ ស្លាប់ទៅក៏បានល្អ មិនមានអ្វីដែលត្រូវកង្វល់ឡើយ ។

ដើម្បីបានសុខក្នុងជីវិត ត្រូវតែមានមិត្តឱ្យបានល្អ
និងមានគំនិតថ្លៃបវរ សន្សំធម៌សសាងជម្រក ។
ជីវិតមានទុក្ខជាធម្មតា ប្រៀបដូចជលសាមានរលក
ប៉ុន្តែបញ្ញាស្រាវជ្រាវរក ចាប់យកសុខស្ងប់ត្រឡប់វិញ។
ដឹងថាទុក្ខពិតតែចិត្តស្ងប់ នេះហើយជាទ្រព្យត្រូវបំពេញ
ទុក្ខកាយតែចិត្តមិនម្នោម្នេញ ជីវិតពោរពេញដោយស្មារតី។
វិញ្ញាណមានធម៌ជាអាហារ ទើបបានសុខាទាំងប្រុសស្រី
សុចរិតធម៌សជាចំណី សិរីសួស្ដីមានរាល់ឆ្នាំ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

ផ្កាឈើជាទីពេញចិត្តនៃសត្វឃ្មុំ យ៉ាងណា របស់ស្អុយទាំងឡាយមានលាមកនិងសាកសពជាដើម ក៏ជាទីពេញចិត្តនៃសត្វរុយ យ៉ាងនោះដែរ ។

បើកូនស្រីសម្លាញ់របស់ឪពុកមានកាយកម្មល្អ មានវាចាល្អ និងមានចិត្តល្អ រមែងប្រៀបដូចជាផ្កាឈើ តែបើកូនមានកាយកម្មមិនល្អ វាចាមិនល្អ និងចិត្តមិនល្អទេ កូនក៏ប្រៀបបាននឹងរបស់ដែលស្អុយដែរ ។

កូនស្រីមាសឪពុក គប្បីជ្រើសយកដោយខ្លួនឯង តើកូនត្រូវការឱ្យរុយវារោម ឬត្រូវឱ្យឃ្មុំមកក្រេប ។

បើកូនស្រីត្រូវការឱ្យឃ្មុំមកទំក្រេប កូនត្រូវបដិបត្តិខ្លួន ឱ្យមានកាយកម្មល្អស្អាត វាចាល្អស្អាត និងចិត្តល្អស្អាត ពោលគឺ កូនត្រូវជាមនុស្សមានសីលមានធម៌ ... ។

បើកូនស្រីប្រព្រឹត្តផ្ទុយពីល្អស្អាត កូនត្រូវបានជួបតែជាមួយរុយ ដែលនាំមកនូវសេចក្តីសៅហ្មងនិងសេចក្តី



វិនាសមកដល់កូនជាពិតប្រាកដ ។

ឃ្មុំក្រេបផ្កា មិនធ្វើឱ្យខូចផ្កា មានតែនាំយកលំអងកេសរទៅធ្វើជាទឹកផ្អែម ឯខ្លួនឯងជាផ្កាសម្រេចបានជាផ្លែ ញ៉ាំងប្រយោជន៍ក្នុងលោកឱ្យបរិបូណ៌ ។

នៅនឹងខ្លួនសត្វឃ្មុំមិនមានមេរោគ មិនមានរបស់ស្មោកគ្រោក មានតែលំអងកេសរផ្កា នេះជាឈ្មោះនៃមនុស្សល្អ បើកូនជាមនុស្សផ្កា កូននឹងមានមនុស្សល្អមករកកូន ញ៉ាំងប្រយោជន៍ឱ្យទូលំទូលាយ ម្យ៉ាងទៀត ឃ្មុំជាឈ្មោះនៃសិរីសួស្តី ។

ឪសូមឱ្យពរដល់កូនស្រី សូមឱ្យកូនស្រីបានទៅជាមនុស្សល្អ ប្រៀបបីដូចជាផ្កាឈើ សូមឱ្យកូនស្រីបានឆ្លងរួចពីការសៅហ្មង កុំជាមនុស្សស្អុយឡើយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com



ឃ្មុំចូលចិត្តរបស់ក្រអូបរបស់ផ្អែម ឯចំណែកសត្វរុយវិញ រមែងចូលចិត្តរបស់ស្អុយរបស់រលួយ ។

កូនប្រុសមាសឪពុក បើកូនចូលចិត្តរបស់ដែលមិនល្អ គឺសេពគប់មនុស្សមិនល្អ គិតមិនល្អ និយាយមិនល្អ ធ្វើមិនល្អ និងទៅកាន់ស្ថានទីដែលមិនល្អហើយ កូនក៏ប្រៀបដូចជា សត្វរុយអ៊ីចឹងឯង ។ បើកូនគិតល្អ និយាយល្អ ធ្វើល្អ សេពគប់មិត្តល្អ និងទៅកាន់តែស្ថានទីដែលល្អៗ កូនក៏ប្រាកដដូចជា ឃ្មុំដោយពិត ។

បើកូនប្រុសជាឃ្មុំ កូនរមែងបានជួបជាមួយនឹងផ្កា តែបើកូនជារុយវិញ កូនរមែងបានជួបតែជាមួយនឹងរបស់ដែលស្អុយរលួយ ។





ក្នុងផែនពសុធានេះ តាំងពីដើមរហូតមក គ្រប់យ៉ាងជារបស់គូគ្នា មានងងឹតមានភ្លឺ មានល្អមានអាក្រក់ ប្រសិនបើឱ្យរើស ចំពោះរបស់ដែលខ្លួនឯងពេញចិត្តហើយ គ្រប់គ្នារមែងប្រាថ្នាតែរបស់ដែលល្អ តែតាមពិតសេចក្តីប្រាថ្នានោះ គឺទាល់តែមានការប្រព្រឹត្តឱ្យបានល្អត្រឹមត្រូវ ទើបអាចសម្រេចទៅបាន ។

ការដើរផ្លូវ ពោលគឺការប្រព្រឹត្តដើម្បីឱ្យបានទៅដល់សេចក្តីល្អសមតាមបំណងប្រាថ្នាគឺ «ការស្រឡាញ់អ្នកដទៃ» ជាការស្រឡាញ់ដោយសេចក្តីរាប់អាន ស្រឡាញ់ដោយមេត្តា ព្រោះថាការស្រឡាញ់អ្នកដទៃបែបនេះ អាចដោះស្រាយនូវបញ្ហាបាន ដោយចំពោះគឺបញ្ហាបៀតបៀន ធ្វើឱ្យលោកនេះមានតែសុខសន្តិភាព «មេត្តាជាធម៌សាងលោក និងទ្រទ្រង់លោក» ។

ការស្រឡាញ់អ្នកដទៃដោយធម៌មេត្តានឹងកើតឡើង

បាន ឪពុកសូមប្រាប់ដល់កូនដូចតទៅ :

១-សូមឱ្យកូនសម្លឹងមើលអ្នកដទៃថាជាមិត្តរួមកើត រួមចាស់ រួមឈឺ រួមស្លាប់ជាមួយគ្នាទាំងអស់ មិនថាអតីត អនាគត ឬបច្ចុប្បន្នឡើយ ។

២-សម្លឹងមើលផ្នែកល្អនៃសត្វលោក និងសម្លឹងមើលបំណងប្រាថ្នានៃសត្វលោក ដែលចង់បានសេចក្តីសុខដូចៗគ្នា ព្រមទាំងសម្លឹងមើលសង្ខារលោកតាមសេចក្តីពិតផង ។

៣-មានសេចក្តីសន្តោស គឺមានការពេញចិត្តតាមមានតាមបានជាភូមិឋានក្នុងជីវិត មានបានយ៉ាងណាក៏ព្រមល្មមយ៉ាងនោះ មិនប្រកាន់ស្អិត ព្រោះឃើញដល់ហេតុដែលសមគួរជាមួយផល សូមឱ្យកូនគិតថា «មានក៏ល្អ មិនមានក៏បាន» ។

ពេញចិត្តចំពោះរបស់ដែលសមគួរ គឺរបស់ដែលបានមកដោយសុចរិត ចិញ្ចឹមជីវិតដោយទ្រព្យត្រជាក់ត្រជំ។

៤-មានការតាំងចិត្តមាំ ឃើញទោសនៃសេចក្តីខ្ជិល



ឃើញគុណប្រយោជន៍នៃសេចក្តីព្យាយាម កាលបានជួបនូវរបស់ដែលមិនជាទីប្រាថ្នា ត្រូវកូនធ្វើទុកក្នុងចិត្តថា លាភយស សុខទុក្ខ សរសើរនិន្ទា អត់លាភអត់យស ជាច្បាប់ធម្មតារបស់ជីវិត បើក្តៅខ្លាំងកូនត្រូវពាក់មួក ឬបាំងឆត្រ កូនមិនត្រូវខឹងប្រទូស្តនឹងក្តៅឡើយ ។

ចំណុចទី១និងទី២ ជាហេតុជិតនៃចិត្តមេត្តា ចំណុចទី៣ សេចក្តីសន្តោស រារាំងលោភៈ ព្រោះបើលោភៈច្រើននាំឱ្យខូចការរាប់អាន រហូតនាំចូលទៅរកការបៀតបៀនទៀតផង ចំណុចទី៤គឺព្យាយាមជាគូនឹងសន្តោស ញុំាងជីវិតឱ្យមានស្ថេរភាព ជាប្រយោជន៍ដល់ការរក្សានូវគុណ-ធម៌ ម្យ៉ាងទៀតការមិនញាប់ញ័រនឹងលោកធម៌ មិនទាស់ចិត្តជាមួយនឹងរបស់ធម្មតា ឈ្មោះថាមានធម៌ជាទីពឹង បុគ្គលមានធម៌ជាទីពឹងរមែងមិនខឹងក្រោធជាមួយអ្នកដទៃឡើយ ។ ចូរកូនចាំទុកថា : ខឹងក្រោធនឹងអ្នកដទៃ គឺលុតជង្គង់អង្វរសូមសេចក្តីសុខពីអ្នកដទៃ ឯការស្រឡាញ់រាប់-អានអ្នកដទៃ ជាការចែកនូវសេចក្តីសុខដែលខ្លួនមានយ៉ាង





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

សម្បូណ៌ឱ្យដល់អ្នកដទៃ ។ បើកូនចេះស្រឡាញ់រាប់អានអ្នកដទៃប្រកបទៅដោយធម៌មេត្តាហើយ កូននឹងបាននូវសេចក្តីល្អសមតាមបំណងប្រាថ្នា បីដូចកូនមាសឪពុកមានទេវតាតាមថែរក្សាអីចឹងឯង ។

មេត្តាប្រែថាការរាប់អាន រកអ្នកដែលបានរួមកើតស្លាប់
គ្រប់គ្នាប្រាថ្នាសុខឆាប់ៗ ប្រញាប់ចង់រួចពីទុក្ខា ។
សត្វលោកស្រឡាញ់ខ្លួនឯងណាស់ កិលេសសែនក្រាស់គ្រប់អាត្មា
ព្រះឱ្យយកខ្លួនជាឧបមា សត្វក្នុងលោកាប្រាថ្នាសុខ។
អធ្យាស្រ័យសត្វមិនដូចគ្នា ចាត់ចែងការងារតាមភូមិស្រុក
ប៉ុន្តែសត្វលោកប្រឹងសម្រុក ធ្វើការយកសុខដូចតែគ្នា ។
កាលណាបានយល់ដូច្នេះហើយ ចម្លើយដ៏ល្អគឺភាវនា
ចម្រើនមេត្តាច្រូចគង្គា ព្រួញពិសក្លាយជាបុប្ផាស្រស់។

✍📖✍



# កូនមាសឪពុក

មនុស្សគ្រប់រូបដែលកើតមកក្នុងលោក រមែងមានការទាក់ទងគ្នាដោយពាក្យនិយាយ ពាក្យនិយាយមានអំណាចដ៏ក្រៃលែង កូនត្រូវយល់ដូចតទៅ :

១-ពាក្យនិយាយអាចដូរផ្លាស់ហេតុអាក្រក់ ឱ្យក្លាយមកជាហេតុល្អបាន ។

២-ពាក្យនិយាយអាចដូរផ្លាស់មនុស្សដែលមានទុក្ខឱ្យភ្លេចទុក្ខបាន ។

៣-ពាក្យនិយាយអាចដូរផ្លាស់មនុស្សខ្ជិល ឱ្យមកជាអ្នកមានព្យាយាមបាន ។

៤-ពាក្យនិយាយអាចដូរផ្លាស់មនុស្សល្ងង់ ឱ្យមកជាមនុស្សឆ្លាតបាន ។

៥-ពាក្យនិយាយ អាចដូរផ្លាស់មនុស្សដែលកំពុងមានកង្វល់ ឱ្យជាមនុស្សស្ងប់បាន ។

៦-ពាក្យនិយាយ អាចដូរផ្លាស់មនុស្សចចេសរឹងរូសឱ្យត្រឡប់មកជាមនុស្សប្រដៅងាយបាន ។

៧.ពាក្យនិយាយ អាចដូរផ្លាស់មនុស្សដែលខូចសតិឱ្យមានសតិវិញបាន ។

៨.ពាក្យនិយាយអាចធ្វើឱ្យមនុស្សឈ្លោះគ្នា ទៅជាល្អនឹងគ្នាបាន ។

ចំពោះពាក្យនិយាយនេះ រមែងមានអំណាចដូចគ្នាដែរ គឺអាចនិយាយឱ្យមនុស្សខូចប្រយោជន៍ និយាយទម្លាយនូវសេចក្តីសុខចម្រើនរបស់អ្នកដទៃ បានគ្រប់យ៉ាងដូច្នេះ កូនត្រូវបដិបត្តិក្នុងការនិយាយឱ្យបានហ្មត់ចត់ កូនត្រូវហាត់និយាយនៅក្នុងវាចាល្អ៥យ៉ាង :

១.និយាយពាក្យពិត មិននិយាយឡេះឡោះ

២.និយាយពាក្យពីរោះ មិននិយាយញុះញង់

៣.និយាយត្រឹមត្រូវតាមកាលៈទេសៈ

៤.និយាយឱ្យបានប្រយោជន៍ដល់អ្នកស្តាប់

៥.និយាយដោយចិត្តមេត្តា ប្រាថ្នាឱ្យអ្នកដទៃបាននូវសេចក្តីសុខ ឬនិយាយដោយចិត្តសប្បុរស ស្មោះត្រង់ មិននិយាយរបៀប ព្រួសពិសដាក់អ្នកដទៃឡើយ ។



## កូនមាសឪពុក

ឪពុកប្រាថ្នាឱ្យកូនបានចូលដល់សេចក្តីល្អ១០ប្រការ :

១.កូនត្រូវជាអ្នកមានសីលធម៌ប្រចាំខ្លួន

២.កូនត្រូវស្វែងរកការចេះដឹងមកដាក់ខ្លួន

៣.កូនត្រូវគប់រកតែជាមួយមិត្តពិតប្រាកដ

៤.កូនត្រូវជាមនុស្សប្រដៅងាយ

៥.កូនត្រូវចេះជួយកិច្ចការអ្នកដទៃ

៦.កូនត្រូវចេះស្រឡាញ់ធម៌សប្បុរស

៧.កូនត្រូវមានព្យាយាមដោយអំណត់អត់ធន់

៨.កូនត្រូវសន្តោសចំពោះបច្ច័យ៤

៩.កូនត្រូវមានស្មារតីដឹងមុខនាទីរបស់ខ្លួន

១០.កូនត្រូវដឹងសេចក្តីពិតរបស់ជីវិត គឺត្រូវដឹងថាគ្រប់ជីវិតដែលកើតមកហើយរមែងបែកធ្លាយជាធម្មតា ទើបមិនគួរប្រមាទក្នុងជីវិត និងត្រូវរកផ្លូវឱ្យបានផុតទុក្ខដោយការប្រព្រឹត្តតែអំពើល្អ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ឪពុកសូមឱ្យកូនកុំជាមនុស្សដែលមិនចេះគ្រប់ សូមឱ្យកូនបានស្គាល់រសជាតិនៃការគ្រប់គ្រាន់ និងសូមឱ្យកូនចាំទុកថា មិនមានរបស់ណាក្នុងលោក ដែលអាចធ្វើឱ្យកូនបានឆ្អែតគ្រប់គ្រាន់ ក្រៅតែពីកូនខ្លួនឯងព្រមគ្រប់នោះឡើយ និងម្យ៉ាងទៀត ក្នុងលោកនេះដែរ មិនមានអ្វីណាដែលល្អសម្រាប់ខ្លួនកូន ឱ្យក្រៃលែងជាងកូនជាមនុស្សល្អនោះទេ ។

សម្បត្តិក្នុងលោកមិនអាចគ្រប់ មិនអាចបញ្ឈប់នូវតណ្ហា
មានតែខ្លួនឯងឈប់ត្រូវការ ដោយសារបញ្ញាទើបបានគ្រប់។
សម្បត្តិក្នុងលោកមិនអាចល្អ ស្មើនឹងធម៌សនាំចាកភព
ធម៌ពិតកូនឪត្រូវសេពគប់ ព្រមទាំងគោរពខ្លួនឯងផង។



# កូនមាសឪពុក

កូនត្រូវយល់ដឹងថា សេចក្តីអត់ធន់ញ៉ាំងនូវផលឱ្យសម្រេចបានគ្រប់យ៉ាង កូនត្រូវអត់ធន់ដូចតទៅ :

១-អត់ធន់ក្នុងរឿងដែលគួរអត់ធន់

២-អត់ធន់ក្នុងរឿងដែលមិនគួរអត់ធន់ ។

ឪសូមអធិប្បាយ គឺមុនដំបូងកូនគួរអត់ធន់ក្នុងរឿងដែលគួរអត់ធន់ ដូចជាអត់ធន់ចំពោះមុខនាទី អត់ធន់ក្នុងការបរិភោគ ការដេក ការរៀន ... ចូរកូនអត់ធន់ដើម្បីអនាគតរបស់កូន សូមឱ្យកូនប្រកាន់ទុកថា សេចក្តីអត់ធន់គឺជាមុខនាទីរបស់យើងមួយផងដែរ ។

តទៅឪសូមឱ្យកូនចេះអត់ធន់ក្នុងរឿងដែលមិនគួរអត់ធន់ ដូចជា យើងធ្វើល្អហើយតែត្រូវគេនិន្ទា ធ្វើល្អដល់គេត្រូវគេប្រទូស្តតបវិញ និយាយពិតធ្វើដោយស្មោះតែត្រូវគេពោលមួលបង្កាច់ ... រឿងទាំងអស់នេះ សុទ្ធតែយើងធ្វើបានត្រឹមត្រូវ មិនគួរអ្វីដែលយើងត្រូវអត់ធន់នោះឡើយ

Document Produced by deskPDF Unregistered :: http://www.docudesk.com

ប៉ុន្តែយើងត្រូវអត់ធន់ទាំងដែលយើងមិនបានខុសនោះឯង សេចក្តីអត់ធន់បែបនេះលំបាកជាទីបំផុត បើកូនធ្វើបាន ឈ្មោះថា កូនល្អដ៏ក្រៃលែង កូននឹងមានសេចក្តីសុខ ផល នឹងកើតមានដល់កូនព្រមទាំងបរិវារ កាលណាបើកូនមាន សេចក្តីអត់ធន់បែបនេះ ។

-សេចក្តីអត់ធន់ ធ្វើឱ្យបានជាមនុស្សចិត្តធ្ងន់

-សេចក្តីអត់ធន់ ធ្វើឱ្យរួចពីក្រញាំតណ្ហា

-សេចក្តីអត់ធន់ ធ្វើឱ្យមានរបៀបវិន័យ

-សេចក្តីអត់ធន់ បញ្ឈប់សេចក្តីក្រោធបាន

-សេចក្តីអត់ធន់ ធ្វើឱ្យតម្កល់ខ្លួនល្អបាន

-សេចក្តីអត់ធន់ ជាដៃគូក្នុងការងារ

-សេចក្តីអត់ធន់ ជាអាវក្រោះរបស់ចិត្ត

-សេចក្តីអត់ធន់ នាំឱ្យមានមិត្ត ខ្សត់សត្រូវ

-សេចក្តីអត់ធន់ ជាបិតានៃគុណធម៌ទាំងពួង ។

ដែកដែលយកទៅដុតដោយភ្លើង ហើយយកមក លត់ដំធ្វើជាឧបករណ៍ផ្សេងៗ រមែងរឹង និងមានតម្លៃ



យ៉ាងណាមិញ មនុស្សដែលអត់ធន់បានល្អ ក៏ជាមនុស្សរឹង-ប៉ឹង និងមានគុណតម្លៃ យ៉ាងដូច្នោះដែរ ។

## ឧទ់ជ័យព្រះពុទ្ធ

ខន្តីប្រែថាការអត់ទ្រាំ រឹងមាំល្អស្រស់ដូចជាទង់
រក្សាកុសលឱ្យគង់វង្ស មេត្តាដូចទង់បក់រវិច ។
មេត្តាខន្តីគូសមស័ក្តិ មិនមានថ្នាំងថ្នាក់អ្វីបន្តិច
គឺអទោសៈថ្លៃជាងពេជ្រ កម្ទេចសត្រូវនៅក្នុងខ្លួន ។
ខ្សែកតញ្ញូបង្គួតទង់ ទ្រទ្រង់បារមីឱ្យមាំមួន
បញ្ញាជាដងយ៉ាងស៊ប់សួន ខ្យល់បក់អង្រួនគឺលោកធម៌។
សតិជាគ្រឹះកប់ក្នុងដី ដងទង់គ្មានអ្វីត្រូវញាប់ញ័រ
ទង់បក់រវិចរំលេចពណ៌ ទទួលលោកធម៌ទាំង៨ ។
ខៀវលឿងក្រហមសហង្សបាទ ពណ៌ផ្លេកស្រស់ស្អាតចាំងរង្សី
ជាផលសម្រេចពីបារមី សីលជាផែនដីទ្រដងទង់ ។

# ក្តួនមាសឪពុក

**មុទិតា** ប្រែថា ត្រេកអរតាម គឺជាដំណើរនៃចិត្ត ដែលទន់ភ្លន់ទៅរកអ្នកដទៃ នៅពេលដែលអ្នកដទៃមាន សេចក្តីសុខ ឬបានលាភបានយស ។

សូមឱ្យមុទិតា ជាអាភរណៈ (គ្រឿងប្រដាប់កាយ) នៃកូនប្រុសស្រីទាំងឡាយ ឪពុកសង្កេតឃើញថា មនុស្ស ចំនួនច្រើន ដោយប្រក្រតីមិនសូវមាននូវមុទិតាជាមួយនឹង អ្នកដទៃឡើយ ។

មុទិតាគឺជាការសម្តែងចេញនូវសេចក្តីត្រេកអរតាម ពោលគឺរួមត្រេកអរទាំងផ្លូវកាយ ទាំងផ្លូវវាចា ទាំងផ្លូវចិត្ត ជាមួយអ្នក ដែលបានជួបប្រសព្វនឹងសេចក្តីសម្រេចនូវផល ប្រយោជន៍នោះៗ ។

មុទិតា ប្រែថា ត្រេកអរតាមដោយចិត្តទន់ភ្លន់ ។

ឥស្សា ប្រែថា មិនត្រេកអរតាម ដោយអំណាចនៃ ចិត្តឫស្យា ពោលគឺការច្រណែន ។



ចូរកូនចាំទុកថា សត្រូវដ៏សំខាន់របស់មុទិតា គឺ ឥស្សា កាលបើច្រណែនហើយ ចិត្តក៏មិនត្រេកអរ មិនមាន ការពេញចិត្ត មានសភាពញាប់ញ័រដូចជាចោរយកសស្ត្រា-វុធមកភ្ជង់ត្រង់ដើមទ្រូងដូច្នោះឯង ។

កាលណាបើបានដឹងថា អ្នកដទៃបានល្អហើយ មិន ថាជាបងប្អូន ជាមនុស្សរួមការងារឬជាអ្នកមានគុណណាៗ ឡើយ អ្នកដែលមានឥស្សាក៏ដល់នូវការស្អុតចិត្តបែបម្យ៉ាង មានការអន់ចិត្ត ... បើមិនទប់ស្កាត់ទេ វានឹងបណ្តាលឱ្យ មានរឿងមិនល្អផ្សេងៗកើតឡើង ដែលជារឿងគួរឱ្យខ្លាច។

វិធីកម្ចាត់ឥស្សា គឺអប់រំចម្រើននូវមុទិតា មានសទ្ធា ជឿហេតុផល មានបញ្ញាយល់ដឹងរឿងក្នុងលោក មិនយល់ ថាសម្បត្តិក្នុងលោកវាអស្ចារ្យណាស់នោះទេ តាមពិត វា គ្រាន់តែសម្រាប់ដោះស្រាយនូវសេចក្តីទុក្ខលំបាកប្រចាំរូប កាយតែប៉ុណ្ណោះ បើរូបកាយមិនមានហើយ ក៏មិនចាំបាច់ ត្រូវការទ្រព្យសម្បត្តិអ្វីបន្តិចបន្តួចឡើយ ដូចជាថ្នាំសម្រាប់ ព្យាបាលរោគ ថ្នាំមិនមែនសំខាន់អ្វីជាងការមិនមានរោគ





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

នោះទេ ដូច្នេះ ខ្លឹមសារសំខាន់ក្នុងជីវិត គឺការប្រព្រឹត្តធម៌ ដើម្បីរំលត់ទុក្ខ ។

កូនត្រូវហាត់អប់រំចម្រើននូវមុទិតា ចាប់ផ្តើមពីក្រុមគ្រួសារទៅមុន រួចហើយផ្សាយពង្រីកទៅដល់អ្នកដទៃជាខាងក្រៅទៀត ឥស្សាក៏នឹងសាបសូន្យទៅ ម្ល៉ោះហើយកូនមាសឪពុកដែលមានតែមុទិតាចំពោះអ្នកដទៃយ៉ាងនេះ សិរីសួស្តី និងសេចក្តីសុខក៏ចូលមករកជីវិតរបស់កូន ព្រមគ្នានឹងគុណធម៌ផ្សេងៗទៀតដ៏ច្រើន ចូរកូនចងចាំកុំភ្លេច មុទិតា មុទិតា មុទិតា ។

មុទិតាជាថ្នាំរម្ងាប់រោគ ឥស្សាស្មោកគ្រោករោគក្នុងចិត្ត
ឥស្សាកើតឡើងអស់អាណិត ដូចខ្មោចសណ្ឋិតនៅក្នុងខ្លួន។
ឥស្សានាំឱ្យមានគំនុំ ធ្វើឱ្យសង្គមមិនមាំមួន
ចាក់ដោតព្យាបាទព្រោះគុំគួន ថៃថូនដោយថ្នាំមុទិតា ។



# កូនមាសឪពុក

ជីវិតមនុស្សគ្រប់គ្នាដែលបានកើតមកនៅក្នុងលោក ហើយមានប្រក្រតីនៅដោយសេចក្តីសុខទៅបាននោះ គឺមកអំពីស្គាល់និងគោរពនូវតួនាទីរបស់ខ្លួនឯង ។

ដើម្បីកូនមាសឪពុកស្គាល់តួនាទី ស្គាល់នូវសិទ្ធិរបស់ខ្លួន សិទ្ធិរបស់អ្នកដទៃ និងដើម្បីរៀបចំទុកដាក់ឱ្យបានល្អក្នុងការសេពគប់ ឬសមាគមរួមការងារក្នុងកិច្ចការផ្សេងៗ ព្រមទាំងដើម្បីឱ្យបានប្រសើរក្នុងការទាក់ទងជាមួយអ្នកដទៃនៅក្នុងសង្គម កូនត្រូវសិក្សារៀនសូត្រឱ្យមានចំណេះដឹង ៧ មុខ :

១-កូនត្រូវរៀនឱ្យដឹងថាកិច្ចការអ្វីខ្លះ ដែលជាមុខនាទីរបស់មនុស្ស ។

២-កូនត្រូវដឹងហេតុ និងផលក្នុងការងារដែលត្រូវធ្វើ មិនត្រូវច្រឡំហេតុផលជាដាច់ខាត ។

៣.កូនត្រូវរៀនអំពីខ្លួនឯង ត្រូវស្គាល់ខ្លួនឯងឱ្យបានប្រាកដ ព្រមទាំងត្រូវដឹងពីការគោរពខ្លួនឯងផង ។

៤.កូនត្រូវរៀនឱ្យដឹងប្រមាណ គឺចេះស្ទង់ស្ទាបក្នុងដំណើរការ មានបញ្ញាយល់ត្រូវជាគ្រឿងកំណត់ ។

៥.កូនត្រូវរៀនអំពីពេលវេលា ត្រូវចេះកំណត់ដឹងកាល ត្រូវចេះប្រើប្រាស់ពេលវេលាឱ្យមានប្រយោជន៍ ។

៦.កូនត្រូវរៀនឱ្យដឹងអំពីព្រឹត្តិការណ៍ និងអធ្យាស្រ័យនៃបុគ្គល ត្រូវចេះសង្កេតឱ្យស្គាល់មនុស្ស ។

៧.កូនត្រូវរៀនឱ្យស្គាល់អំពីសង្គមមនុស្ស ទំនៀមទម្លាប់ប្រពៃណី ... ។

ចំណេះដឹងទាំងអស់នេះ មិនត្រឹមតែធ្វើឱ្យកូនស្គាល់នូវតួនាទីរបស់ខ្លួនបានច្បាស់លាស់ប៉ុណ្ណឹងទេ គឺនៅធ្វើឱ្យកូនបានទៅជាមនុស្សដ៏សំខាន់ ក្នុងការជួយខ្លួនឯង និងជួយដល់អ្នកដទៃទៀតផង ប៉ុន្តែឪសូមឱ្យកូនមាននូវស្មារតីប្រយ័ត្នជានិច្ចចំពោះសេចក្តីប្រមាទ គឺការធ្វេសប្រហែស ព្រោះសេចក្តីប្រមាទនេះឯង វាអាចធ្វើឱ្យអ្នកដែល



ចេះស្ទាត់ក្នុងការងារហើយនោះ ត្រឡប់ទៅជាទទួលនូវបរាជ័យ ដូចបុគ្គលល្ងង់ខ្លៅ ឬដូចជារថយន្តដែលក្រឡាប់ធ្លាក់ជ្រោះអីចឹងឯង ។

កូនមាសឪពុក តួនាទីរបស់មនុស្សជាកិច្ចការចាំបាច់បំផុតដែលត្រូវសិក្សា និងបដិបត្តិដល់គ្នាទៅវិញទៅមក ក្នុងខណៈនេះកូនមានតួនាទីច្រើនយ៉ាងដែលត្រូវធ្វើចំពោះអ្នកដទៃ ។

កូនត្រូវបំពេញតួនាទីជាកូនដ៏ល្អរបស់មាតាបិតា ។

កាលកូនជាបងគេ កូនត្រូវបំពេញតួនាទីជាបងដ៏ល្អរបស់ប្អូន ។

កាលកូនជាប្អូនគេ កូនត្រូវបំពេញតួនាទីជាប្អូនដ៏ល្អរបស់បង ។

កាលកូនជាមិត្តរបស់គេ កូនត្រូវបំពេញតួនាទីជាមិត្តដ៏ល្អរបស់មិត្តសម្លាញ់ ។

កាលកូនជាអ្នករៀនសូត្រ កូនត្រូវបំពេញតួនាទីជាសិស្សល្អរបស់គ្រូ ។ល។



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

គ្រប់យ៉ាងត្រូវឱ្យល្អជាទីបំផុត និងឱ្យអស់សមត្ថ-
ភាព ។

## ការបដិបត្តិនូវតួនាទីជាមនុស្សគឺជាការ
## បដិបត្តិនូវធម៌ដ៏សមគួរតាមធម៌

តួនាទី ត្រូវសំភី ធ្វើឱ្យល្អ
ចិត្តស្មោះស បន្តការ ស្មារតីមាន
មិនប្រមាទ ក្នុងជីវិត ពិតជាស្ពាន
ចាកអត់ឃ្លាន ឈានឆ្លងគ្រោះ រស់ប្រពៃ ។
ខ្ជិលធ្វើការ មានឈ្មោះថា ស្លាប់ទាំងរស់
ស្លាប់ដូចពស់ រស់កង្កែប បែបសត្វវៃ
ហេតុដូច្នេះ កូនត្រូវចេះ ឆ្លាតវាងវៃ
កម្ចាត់ភ័យ លៃឱ្យសព្វ ញាប់ដៃជើង ។



## កូនមាសឪពុក

កូនមានតួនាទីរបស់កូន ដែលត្រូវបដិបត្តិចំពោះ
មាតាបិតាដូចខាងក្រោមនេះ :
១-តាំងចិត្តសិក្សារៀនសូត្រដើម្បីឱ្យបានជាកូនចេះដឹង ។
២-ជួយធ្វើកិច្ចការមាតាបិតាឱ្យបានល្អជាទីបំផុត ។
៣-តម្កល់តម្កើងនូវវង្សត្រកូលឱ្យបានល្អតទៅ ។
៤-ប្រព្រឹត្តខ្លួនឱ្យល្អ ឱ្យសមគួរជាអ្នកទទួលនូវមរតក ។
៥-មាតាបិតាចិញ្ចឹមកូនឱ្យរស់មក កូនត្រូវចិញ្ចឹមមាតាបិតា
វិញជាពិសេសនៅពេលគាត់ចាស់ទៅហ្នឹងឯង ។
៦-នាំមាតាបិតាទៅវត្ត ឬកន្លែងផ្សេងៗតាមសមគួរ ។
៧-នៅពេលមាតាបិតាមានជំងឺ ត្រូវនៅថែរក្សាឱ្យបានដិត-
ដល់ ត្រូវជួយឱ្យមាតាបិតាបានស្តាប់ធម៌ផង ។

៨.ត្រូវរក្សាទឹកចិត្តរបស់មាតាបិតា មិនឱ្យមាតាបិតាមានទុក្ខកង្វល់ ឬខូចចិត្តដោយសាររឿងមិនល្អរបស់ខ្លួនជាកូនឡើយ ត្រូវចាំទុកថា **សេចក្តីសុខរបស់មាតាបិតា នៅត្រង់កតញ្ញូតាធម៌របស់កូនទាំងឡាយ** ។

៩.ត្រូវថែរក្សានូវទ្រព្យសម្បត្តិផង អវយវៈខ្លួនប្រាណទាំងមូលផង ជីវិតផង និងឱវាទទូន្មានផ្សេងៗផង ដែលមាតាបិតាបានប្រគល់ឱ្យមកកូន ។

១០.ធ្វើបុណ្យឧទ្ទិសជូនដល់មាតាបិតា កាលគាត់ធ្វើកាលកិរិយាទៅកាន់បរលោកហើយ ។



## កូនមាសឪពុក

កាលកូនជាអ្នករៀនសូត្រគឺជាសិស្ស កូនមានតួនាទីទាក់ទងនឹងការសិក្សាដូចខាងក្រោមនេះ :

១.ត្រូវសម្តែងការគោរពចំពោះលោកគ្រូ អ្នកគ្រូ ដោយសេចក្តីកោតក្រែង ។

២.បើមានឱកាសត្រូវប្រញាប់ចូលទៅទទួលបម្រើគ្រូក្នុងកិច្ចការដ៏សមគួរ ។

៣.ត្រូវស្តាប់គ្រូ និងបដិបត្តិតាមការណែនាំរបស់លោកគ្រូ អ្នកគ្រូ ដោយយកចិត្តទុកដាក់ ។

៤.តាំងចិត្តរៀនគ្រប់ចំណេះវិជ្ជាដែលគ្រូនាំមកបង្រៀន ។

៥.ត្រូវបដិបត្តិឱ្យមាននូវរបៀបវិន័យ តាមបទបញ្ជារបស់សាលា ត្រូវទុកវិន័យដូចជាអលង្ការ ។

៦.ត្រូវជួយធ្វើការងាររបស់សាលាតាមការឆ្លាតឈ្លាសរបស់ខ្លួន និងមិនត្រូវខ្ជិលជាដាច់ខាត ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

៧-ត្រូវជួយរក្សាទ្រព្យសម្បត្តិរបស់សាលារៀនឱ្យគង់វង្ស។

៨-ត្រូវមានសេចក្តីស្រឡាញ់រាប់អានចំពោះសិស្សសាលាផងគ្នា ត្រូវធ្វើជាសិស្សគំរូល្អ ។

៩-មានឆន្ទៈពេញចិត្តក្នុងការសិក្សា ព្រោះការសិក្សាជាការស្វែងរកចំណេះដឹងមកដាក់ក្នុងខ្លួន ត្រូវព្យាយាមឱ្យបានសម្រេច មិនខ្ជិល មិនគិតតែពីលេងសប្បាយ ត្រូវយកចិត្តទុកដាក់ចំពោះកិច្ចការ និងត្រូវចេះពិចារណាក្នុងហេតុផលផ្សេងៗ ចេះសាកសួរដើម្បីឱ្យការចេះដឹងបានត្រឹមត្រូវ ។

១០-ត្រូវចេះប្រយ័ត្នចំពោះចំណង់ ដែលចង់ក្នុងផ្លូវអាក្រក់ផ្សេងៗ ត្រូវរៀនឱ្យចេះអត់ធន់ ដើម្បីបានជាដៃគូក្នុងការសិក្សា កូនត្រូវដឹងថា **សេចក្តីអត់ធន់គឺជាវិជ្ជាដ៏សំខាន់និងជាឫសគល់នៃចំណេះដឹងទាំងឡាយ** និងត្រូវចាំទុកថា **បុគ្គលល្ងង់ខ្លៅមានខ្លួនឯងជាសត្រូវ** ។



## កូនមាសឪពុក

នាទីដែលកូនត្រូវបដិបត្តិចំពោះអ្នកដទៃជាទូទៅដោយការឱ្យនូវទឹកចិត្តល្អស្មោះរបស់កូន :

១-កូនត្រូវសម្លឹងមើលមនុស្សគ្រប់គ្នា ដែលបានជួបដោយក្រសែភ្នែកជាមិត្ត ។

២-កូនត្រូវចេះញញឹម ឬមានទឹកមុខស្រស់ស្រាយជាមួយមនុស្សទាំងឡាយ ។

៣-កូនត្រូវចេះសម្លឹងមើលផ្នែកល្អរបស់មនុស្ស កូនត្រូវយល់ថា អ្នកដែលបានកើតមកជាមនុស្សសុទ្ធតែជាអ្នកធ្លាប់បានធ្វើល្អ កូនមិនត្រូវមាក់ងាយអ្នកណាឡើយ ។

៤-កូនត្រូវចេះគួរសមដោយរបៀបល្អគ្រប់យ៉ាង ដូចជាញញឹមរក សំពះ ឱនក្បាលបន្ទន់ខ្លួន ... តាមឋានៈរបស់ខ្លួន និងតាមឋានៈរបស់អ្នកដទៃ ។

៥-កូនត្រូវចេះស្តាប់អ្នកដទៃនិយាយ កុំនិយាយកាត់ដោយឥតរបៀប បើនិយាយ ត្រូវឱ្យមានប្រយោជន៍ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

៦.កូនត្រូវចេះប្រើពាក្យទាំងពីរយ៉ាងនេះ ឱ្យជាប្រចាំ គឺពាក្យសូមអរគុណ និង ពាក្យសូមអត់ទោស ។

៧.កូនត្រូវនិយាយដោយពាក្យសុភាព ពីរោះទាំងចំពោះមុខទាំងកំបាំងមុខ ។

៨.កូនត្រូវចេះឱ្យកម្លាំងចិត្ត ដោយពាក្យសរសើរជាដើមដល់មនុស្សល្អ ។

៩.កូនត្រូវចេះនិយាយសរសើរ ក្នុងផ្នែកល្អរបស់មនុស្សណា ដែលជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដែលកូនកំពុងតែនិយាយជាមួយ ជាការសរសើរពិតៗ ។

១០.កូនត្រូវចេះបដិសេធនូវអ្វី ដែលកូនមិនយល់ស្របតាមដោយមិនឱ្យគេខូចចិត្ត ។

១១.កូនត្រូវរួមសន្ទនាក្នុងអ្វីដែលអ្នកសន្ទនាអាចឱ្យការចេះដឹងមកកូនបាន ។

១២.កូនត្រូវយករឿងល្អៗ ឬរឿងអ្នកធ្វើល្អមកនិយាយក្នុងពេលសន្ទនា ។

១៣.កូនត្រូវអាស្រ័យបញ្ញា ពិចារណាចំពោះអ្នកដទៃដែល



នៅជុំវិញខ្លួនកូន ដោយកូនមិនត្រូវអាងអំណាចអ្វីមួយហើយចាំតែចាប់កំហុសគេឡើយ ។

១៤.កូនគួរតែរកពេលវៀរចាកការនិយាយមិនល្អ ឬវៀរចាកការខឹងក្រោធ យ៉ាងតិចឱ្យបានមួយថ្ងៃក្នុងមួយសប្តាហ៍ ទោះជាថ្ងៃណាក៏បានដែរ ។

១៥.កូនត្រូវសាងឧបនិស្ស័យជួយអ្នកដទៃ ក្នុងការងារអ្វីដែលកូនអាចធ្វើបាន ដោយមិនសម្លឹងផលតបស្នងពីគេវិញ ត្រូវសន្សំសន្ដានករុណាឱ្យកាន់តែមាំទាំ មុននឹងលាចាកលោកនេះទៅ ។

## ទឹកចិត្តល្អបីដូចជាព្រះព្រហ្មដែលស្ថិតក្នុងខ្លួនមនុស្ស

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

ឪសូមទូន្មានកូនថា :

គប់ពាលៗនាំទៅរកខុស ស្រីប្រុសចូរចាំកុំតាមចង់
គប់ប្រាជ្ញៗនាំទៅរកត្រង់ សីលល្អផ្លូវផង់ចង់ត្រឹមត្រូវ។
សេពគប់បាបមិត្តពិតនាំខ្លួន ឱ្យខុសផ្លូនៗកើ្តអាស្រូវ
កំណើតជាមនុស្សក្រពេកក្ូវកូនត្រូវស្តាប់ឪទើបឈ្មោះល្អ។

**ចង់កសាងខ្លួនកុំឆ្ងាយអ្នកប្រាជ្ញ**



## កូនមាសឪពុក

កូនត្រូវចាំជានិច្ចថា :

ការឈ្នះដ៏ក្រៃលែងជាទីបំផុត គឺការឈ្នះចិត្តខ្លួនឯង ព្រោះហេតុនេះ កូនត្រូវហ្វឹកហាត់បង្គាប់ខ្លួនឯងឱ្យបាន កាលដែលកូនបង្គាប់ខ្លួនឯងបានហើយ កូនធ្វើអ្វីៗក៏បានសម្រេចដែរ ។

**ឈ្នះខ្លួនឯងប្រសើរជាង**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

ការសម្តែងសេចក្តីគោរព ដាក់ខ្លួនឱនលំទោន ជាមារយាទនៃមនុស្សល្អ ។

កូនកុំអួតអាងលើកតម្កើងខ្លួនជាមួយនឹងអ្នកណាៗឱ្យសោះ ព្រោះវាមិនបានឱ្យផលល្អដល់ដំណើរជីវិតរបស់កូនឡើយ ។

**ការលើកតម្កើងខ្លួនឯងមិនមែនជាការគោរពខ្លួនទេ**



## កូនមាសឪពុក

កូនចូរញញឹមដាក់អ្នកដទៃ ដូចដែលកូនប្រាថ្នាឱ្យអ្នកដទៃញញឹមមករកកូនអ៊ីចឹងដែរ ។

បើកូនញញឹមដាក់កញ្ចក់ កញ្ចក់ក៏ញញឹមដាក់កូនវិញ នៅពេលកូនខឹងក្រោធនឹងបុគ្គលណា កូនសាកល្បងរត់ទៅឆ្លុះមុខខ្លួនឯងក្នុងកញ្ចក់មើល កូននឹងជួបយក្សនៅក្នុងកញ្ចក់នោះពិតជាមិនខានឡើយ ។

**បើចង់ឱ្យមុខស្អាតត្រូវកុំខឹង**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

ការស្រឡាញ់មិនមានដាក់លក់ឡើយ បើកូនចង់បាន កូនត្រូវធ្វើយកដោយខ្លួនឯង ។

ពេលកូនឱ្យសេចក្តីស្រឡាញ់ទៅអ្នកដទៃ អ្នកដទៃនឹងឱ្យសេចក្ដីស្រឡាញ់ត្រឡប់មកដល់កូនវិញ ។

បើកូនចង់ឱ្យអ្នកដទៃស្រឡាញ់ពិតៗ សូមកូនធ្វើឱ្យបានតែម្យ៉ាងក៏ល្មមគ្រប់គ្រាន់ គឺ ធ្វើខ្លួនឱ្យគួរស្រឡាញ់ ។

**ស្រឡាញ់អ្នកដទៃដោយមេត្តាជាការប្រសើរ**



## កូនមាសឪពុក

រាល់យប់មុននឹងចូលគេង កូនកុំភ្លេចថ្វាយបង្គំព្រះ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយកូនត្រូវនឹកដល់គុណមាតាបិតាផង ព្រមទាំងអ្នកមានគុណផ្សេងៗទៀតផងដែរ បើកូនធ្វើបានដូចនេះ កូននឹងបានចម្រើន... អូ ! សូមកូនកុំភ្លេចតាំងចិត្តមេត្តាដល់សត្វទាំងឡាយផងណា៎ !

**ប្រះខ្លួនដេកទៅកុំដេកទទេ**

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

បើកូនចង់ស្អាត... ត្រូវរក្សាសីល

បើកូនចង់មាន... ត្រូវឱ្យទាន

បើកូនចង់ឆ្លាត... ត្រូវចេះសួរ

បើកូនរៀនដើម្បីនឹងដឹងអ្វីណាមួយ ត្រូវរៀនដឹងឱ្យច្បាស់លាស់ពិតប្រាកដ កូនមាសឪពុករៀនដឹងដើម្បីជួយខ្លួនឯង គឺដើម្បីមានខ្លួនឯងជាទីពឹង ។

**ពឹងខ្លួនឯងបាន ប្រសើរជាងពឹងអ្នកដទៃ**



# កូនមាសឪពុក

ភាសិតបានពោលទុកថា :

អ្នកស្រែបានស្រូវ រមែងឱ្យបាយ
ពួកព្រានទាំងឡាយរមែងឱ្យសាច់
ពេទ្យព្យាបាលរោគ ជាកិច្ចចាំបាច់
ឱ្យទានសម្រេចទៅលើចិត្តបុណ្យ។
ចំណែកបណ្ឌិត មានពិតក្នុងលោក
បានជួបមានជោគព្រោះលោកពោលសុន្ទរ៍
កូនចង់បានអ្វី កុំឱ្យស៊យស៊ុន
គិតទុកជាមុន សឹមចូលទៅរក ។

**ធម្មទានឈ្នះអស់ទានទាំងពួង**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនចូរសម្តែងការរីករាយដល់អ្នកដែលឈ្នះកូនគ្រប់ករណី ដើម្បីដល់ថ្ងៃក្រោយតទៅ នៅពេលដែលកូនឈ្នះគេវិញ គេនឹងសម្តែងការរីករាយមករកកូនដូចគ្នាដែរ ប៉ុន្តែបើគេមិនបានសម្តែងការរីករាយមករកកូនទេនោះ កូនក៏គួរសម្តែងនូវការយល់ដល់ចិត្តរបស់គេ និងអាណិតគេផង ព្រោះគេបានចាញ់តាំងតែពីគ្រាដំបូងដែលគេបានឈ្នះកូនម្ល៉េះ គឺចាញ់ចិត្តរបស់ខ្លួនគេហ្នឹងឯង ចំណែកកូនវិញ គឺឈ្នះចិត្តរបស់កូន ដែលជាការឈ្នះដ៏ប្រសើរ ។

**មិនមានការតស៊ូណា ឱ្យក្រៃលែងជាង**
**ការតស៊ូយកឈ្នះចិត្តអាក្រក់របស់ខ្លួនឡើយ**



## កូនមាសឪពុក

កូននៅទីកន្លែងណាៗក៏ដោយ កូនចូរចាំទុក មិនត្រូវធ្វើខ្លួនឱ្យមានបញ្ហា ត្រូវតែធ្វើខ្លួនឱ្យអស់បញ្ហា កុំរវល់ចាប់ទោសអ្នកដទៃ ហើយត្រូវតម្កល់ខ្លួនឯងទុកឱ្យប្រពៃ ។

**មនុស្សល្អគឺមនុស្សដែលចេះទូន្មានខ្លួនឯង**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនមិនត្រូវនិន្ទា និយាយអាក្រក់ពីក្រោយអ្នកដទៃឡើយ ព្រោះបើគេបានដឹងរឿងហើយ គេរមែងមានទុក្ខនិងខឹងក្រោធមករកកូនវិញ ទោះបីនៅចំពោះមុខក៏ដោយបើកូនចង់និយាយអ្វី កូនត្រូវតាំងចិត្តមេត្តាឱ្យបានស្រួលសិន សឹមនិយាយ កូនកុំភ្លេចគិតថា ឪពុកម្តាយគេ ឪពុកម្តាយយើង បងប្អូនគេ បងប្អូនយើង ... ។

**នៅតែម្នាក់ឯងឱ្យប្រយ័ត្នគំនិត**
**នៅជាមួយញាតិមិត្តឱ្យប្រយ័ត្នសម្តី**



## កូនមាសឪពុក

កូនមិនគួរគប្បីកើតមកដើម្បីមានសេចក្តីទុក្ខលំបាកឡើយ ក្នុងវ័យក្មេងកូនត្រូវរកសេចក្តីសុខជាមួយនឹងការរៀនសូត្រព្រមដោយរៀនដឹងរឿងជីវិត ក្នុងវ័យកម្លោះក្រមុំកូនត្រូវរកនូវសេចក្តីសុខជាមួយនឹងការកសាងជីវិត រៀបចំជីវិតទៅតាមការចេះដឹង ក្នុងពេលគ្រប់គ្រងផ្ទះកូនត្រូវរកសេចក្តីសុខជាមួយនឹងជីវិតគ្រួសារ ក្នុងវ័យជរាកូនត្រូវរកនូវសេចក្តីសុខជាមួយនឹងសេចក្តីស្ងប់ផ្លូវចិត្ត ។

**ការបានបញ្ញានាំមកនូវសេចក្តីសុខ**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនគប្បីនឹកជានិច្ច នៅពេលដែលកូនមានការធុញទ្រាន់ក្នុងការរៀនសូត្រ សូមកូនគិតថា ការរៀនសូត្រជាទ្វារចូលទៅរកសេចក្តីសម្រេច ការរៀនសូត្រជាទ្វារចូលទៅរកសេចក្តីសុខ ការរៀនសូត្រជាទ្វារចូលទៅរកជ័យជម្នះ។

**វិជ្ជាទុកជាភ្នែក**
**ការប្រព្រឹត្តទុកជាជើង**



## កូនមាសឪពុក

បើកូនប្រាថ្នាជាមនុស្សល្អ កូនគួរដឹងពេលវេលានិងគួរបដិបត្តិឱ្យត្រូវពេល :

-ដល់ពេលញ៉ាំកូនត្រូវញ៉ាំ

-ដល់ពេលគេងកូនត្រូវគេង

-ដល់ពេលក្រោកកូនត្រូវក្រោក

-ដល់ពេលរៀនកូនត្រូវរៀន

-ដល់ពេលលេងកូនសឹមលេង

-ដល់ពេលដែលត្រូវធ្វើនូវអ្វីណា កូនត្រូវតែធ្វើនូវអ្វីនោះ ឱ្យពិតប្រាកដ ។

**ពេលវេលានាំពាស៊ីនូវសព្វសត្វ**

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

បើកូនជួយខ្លួនឯងមិនបាន អ្នកខុសគឺពុកនិងម៉ែ តែបើកូនជួយខ្លួនឯងបាន អ្នកដែលសប្បាយចិត្តជាងគេគឺឪពុកម្តាយរបស់កូនហ្នឹងឯង ។

ពេលមានបញ្ហាទាក់ទងនឹងកូន ត្រូវកូនរកហេតុនៃបញ្ហា ហើយយកមកពិចារណាកែខៃ កូនត្រូវដោះស្រាយបញ្ហាដោយបញ្ញា កុំដោះស្រាយបញ្ហាដោយការខឹងក្រោធឱ្យសោះ ។

**នៅពេលខឹងមនុស្សយើងតែងតែល្ងង់**

✍📖✍



# កូនមាសឪពុក

កូនកុំជាម្ចាស់បំណុលឡើយ ព្រោះធ្វើឱ្យកូនមានទុក្ខ។ កូនកុំចូលចិត្តខ្ចីរបស់របរប្រើប្រាស់ សំពត់ខោអាវអ្នកដទៃ កូនត្រូវចាត់ចែងត្រៀមរៀបចំឱ្យមានព្រម បើមិនមាននិងមិនចាំបាច់ទេ គឺមិនត្រូវប្រើនូវរបស់នោះឡើយ ។

**មារយាទល្អជាសម្បត្តិដ៏ប្រពៃ**

✍📖✍

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

បើកូនមិនចង់ឱ្យបែកមិត្ត កូនកុំខ្ចីប្រាក់មិត្ត ឯការចូលចិត្តសូម រឹតតែកុំណាស់ទៅទៀត ។

ការលួចរបស់អ្នកដទៃ ខុសទាំងច្បាប់ ខុសទាំងសីលធម៌ នាំឱ្យមានពៀរវេរាទៀតផង ។

កូនចូរចាំទុកថា ទ្រព្យសម្បត្តិមាសប្រាក់របស់យើង ចោរអាចលួចយកទៅបាន តែចំណេះវិជ្ជានៅជាប់ជាមួយនឹងខ្លួន អ្នកណាក៏លួចយកទៅមិនបានដែរ ។

### វិជ្ជាជាកំណប់ទ្រព្យជាប់នឹងខ្លួន



## កូនមាសឪពុក

កូនកុំទៅផ្ទះគេញឹកញាប់ពេក ព្រោះគេអាចធុញទ្រាន់មិនចង់ទទួល រឿងនេះកូនអាចសង្កេតបានដោយខ្លួនឯង បើអ្នកណាមកផ្ទះយើងញយៗ កូនក៏មិនពេញចិត្តដែរ ព្រោះដូច្នេះ កូនមាសឪពុកកុំទៅផ្ទះគេញាប់ពេក ។

### ទៅរកគេឱ្យគេត្រេកអរ
### នេះជាដំណើររបស់មនុស្សល្អ

# កូនមាសឪពុក

បើកូនទៅផ្ទះអ្នកដទៃ កុំចូលបន្ទប់ដេករបស់គេ វៀរតែគេអនុញ្ញាត កាលចូលទៅហើយកុំរើមរវាមរុះរើអ្វីឡើយ ហើយកូនមានតួនាទីសរសើរនូវអ្វីដែលកូនគួរសរសើរ ។

នាទីរបស់កូនក្នុងឋានៈជាភ្ញៀវ ៖

១-សម្តែងការគោរពដល់បុគ្គលជាធំដែលគួរគោរព

២-ឱ្យការស្និទ្ធស្នាលនិងភាពជាមិត្តដល់អ្នកតូច

៣-ឱ្យការរីករាយដល់ម្ចាស់ផ្ទះ ឬម្ចាស់កន្លែងនោះដោយពាក្យសរសើរ ត្រូវប្រយ័ត្នក្នុងការរិះគន់និន្ទានូវរឿងអ្វីមួយ ។

**ភ្ញៀវល្អដូចជាផ្កាដែលគេចូលចិត្ត**



# កូនមាសឪពុក

ការក្រែងចិត្តជាសម្បត្តិរបស់មនុស្សល្អ បើកូនទៅណាមកណា កុំឱ្យគេរង់ចាំ ។

មុននឹងកូនទៅទីណា កូនត្រូវប្រាប់អ្នកធំក្នុងផ្ទះ ឬក្នុងកន្លែងនោះ កាលគេបានដឹងហើយ គេនឹងជួយទំនុកបម្រុងកូនក្នុងកិច្ចការដែលចាំបាច់ ។

**សុជីវធម៌កើតមកពីការក្រែងចិត្តអ្នកដទៃ**





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

កូននៅទីណាក៏ដោយ មិនត្រូវសាងសត្រូវឡើយ បើកូនជាមិត្តនឹងមនុស្សគ្រប់គ្នា មនុស្សគ្រប់គ្នាក៏ជាមិត្តជាមួយនឹងកូនដែរ ។

កូនចូរនឹករលឹកជានិច្ចថា :

នៅលើផែនដីនេះ បើយើងមានសត្រូវតែម្នាក់ ក៏វាច្រើនណាស់ទៅហើយ ។

ចូរកូនកុំពេញចិត្តធ្វើឱ្យគេស្អប់ ទាំងកូនខ្លួនឯងក៏កុំចូលចិត្តស្អប់អ្នកដទៃឡើយ ។

## សាងមិត្តកុំសាងសត្រូវ



# កូនមាសឪពុក

បើអ្នកដទៃធ្វើខុសមកលើកូន ចូរកូនកុំយកកំហឹងទៅទប់ទល់ឱ្យសោះ កូនត្រូវឱ្យអភ័យ ហើយត្រូវសម្លឹងទៅរកសេចក្ដីល្អរបស់គេឱ្យបានច្រើន បើកូនរកអំពើល្អរបស់គេមិនឃើញទេ កូនត្រូវតែអាណិតគេ ព្រោះគេកំពុងតែមានគ្រោះកាច ។

ចូរកូនមាសឪពុកចាំទុកថា :

គេមានផ្នែក ប៉ែកមិនល្អ កូនកុំឃ្នើស
កូនត្រូវជ្រើស រើសយកស ល្អគេមាន
ជាប្រយោជន៍ ហោចប្រកាន់ ឆ្ពោះនិព្វាន
ខុសប៉ុន្មាន ជាបាបគ្រោះ របស់គេ ។

## ការគ្រប់គ្រងចិត្តនាំមកនូវសេចក្ដីសុខ

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

កូនកុំឈ្លោះជាមួយអ្នកដទៃ កូនកុំនិយាយអាក្រក់ពីគេ កូនកុំមើលងាយមើលថោកដល់អ្នកណាៗឡើយ ។

កូនកុំខឹងក្រោធដាក់អ្នកដទៃងាយៗ បើកូនខឹង កូនត្រូវដើរទៅងូតទឹក ទៅអានសៀវភៅ ... ហើយកូនត្រូវទន្ទេញពាក្យថា ឱ្យអភ័យ ឱ្យអភ័យ ។

**អភយទានជាទានដ៏ប្រសើរ**

✍📖✍



# កូនមាសឪពុក

កូនត្រូវជួយអ្នកដទៃ ជួយដោយស្មោះត្រង់ ជួយដោយការនិយាយ ជួយដោយការប្រឹក្សា ជួយដោយកម្លាំងកាយ ក្នុងការងារដែលត្រឹមត្រូវ ការជួយអ្នកដទៃធ្វើឱ្យកូនបានសប្បាយចិត្ត នៅពេលដែលការងារបានសម្រេច ។

ទឹកចិត្តល្អ គឺជាទីប្រាថ្នារបស់មនុស្សក្នុងលោក ឪសូមឱ្យកូនមានទឹកចិត្តល្អដល់មនុស្សសត្វទាំងឡាយ ។

**ទឹកចិត្តល្អប្រៀបដូចជាទឹកបរិសុទ្ធ**

✍📖✍

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

ឪពុកម្តាយមានតែចាស់ទៅ នឹងនៅចិញ្ចឹមកូនរហូត មិនបានឡើយ ត្រូវកូនរកវិជ្ជាជួយខ្លួនឯង បើកូនបានសុខ ឪពុកម្តាយសប្បាយចិត្ត ។

ពុកនិងម៉ែ តែប៉ុណ្ណេះ ចេះតែចាស់
ប្រាកដណាស់ ច្បាស់ជាព្រាត់ ឃាត់មិនបាន
កូនត្រូវខំ នាំវិជ្ជា មកដាក់ប្រាណ
ទើបកូនបាន ទីពំនឹង ពឹងអាស្រ័យ ។

**មនុស្សអត់វិជ្ជាដូចនាវាអត់ចង្កូត**

-៦៥-

## កូនមាសឪពុក

កូនចូរអប់រំចិត្ត ឱ្យចេះព្រមទទួលនូវសេចក្តីពិតនៃជីវិត កូនមិនចាំបាច់ចង់ឱ្យអ្វីៗនៅដដែលនោះទេ ព្រោះវាមិនបានដូចចង់ឡើយ ហើយកាលមិនបានដូចចង់ក៏ជាទុក្ខ។

ចូរកូនចាំទុកថា :

ដរាបណាមនុស្សយើងនៅមិនទាន់ស្លាប់ទេ ដរាបនោះ មនុស្សយើងនឹងបានជួបនូវរបស់ដែលប្រែប្រួលរហូតជានិច្ច នេះជាសេចក្តីពិតក្នុងដំណើរជីវិត ។

**មិនទំនាស់នឹងរបស់ពិតទើបបានសុខ**

-៦៦-

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

បើកូនស្អប់គេខ្លាំង កូនក៏មានទុក្ខខ្លាំងដែរ បើកូនស្អប់គេតិច កូនក៏មានទុក្ខតិចដែរ បើកូនមិនស្អប់គេទេ កូនមិនមានទុក្ខឡើយ ។

ការស្អប់គ្នានឹងគ្នា ធ្វើឱ្យលោកនេះមានការបែកបាក់ ព្រោះវាជាការទម្លាយគ្នានៅក្នុងលោកទាំងមូល ។

ចូរកូនកុំក្រោធ កុំស្អប់គ្នាឡើយ ចូរកូនគិតថា ក្រោធគឺល្ងង់ មោហោគឺឆ្កួត មិនក្រោធល្អជាង នឹងបានជាអ្នកមិនល្ងង់មិនឆ្កួត ។

បុរាណបានពោលថា

**បើឆ្កែខាំកុំខាំឆ្កែវិញ**



# កូនមាសឪពុក

មាសប្រាក់ដែលម៉ែឪរកមកឱ្យកូន សម្រាប់សិក្សារៀនសូត្រ សូមឱ្យកូនចាយវាយយ៉ាងប្រយ័ត្ន កូនមិនត្រូវខ្ជះខ្ជាយឡើយ ។

ចេះញាំ ចេះប្រើ ចេះទុកដាក់ ... ដូច្នេះ កូនរមែងមិនលំបាក ហើយតទៅកូននឹងអាចជួយអ្នកដទៃបានទៀតផង ។

**គំនិតចាត់ទុកជាលេខ ១**

**ជំនួយចាត់ទុកជាឧបករណ៍**

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

ព្រះសម្មាសម្ពុទ្ធបានទូន្មានទុកមកថា : យើងសេពគប់មនុស្សយ៉ាងណា យើងក៏ជាមនុស្សយ៉ាងនោះ ដូចនិទានអំពីសត្វសេកមួយគូ សេកមួយទៅនៅនឹងតាបស សត្វសេកមួយទៀតទៅនៅនឹងពួកចោរ ដូចដែលឪធ្លាប់បាននិទានឱ្យកូនស្តាប់ហើយ គឺថា សេកមួយល្អ សេកមួយអាក្រក់ ។

បើកូននឹងសេពគប់ជាមួយអ្នកណា ត្រូវឱ្យប្រយ័ត្នប្រយែង កូនត្រូវតែគិតជានិច្ចថា នឹងមិនយកតម្រាប់តាមមនុស្សអាក្រក់ឡើយ ។

## មិនសេពគប់មិនមែនបានន័យថាស្អប់ទេ



# កូនមាសឪពុក

កូននឹងរស់នៅក្នុងលោកនេះបានយ៉ាងមានសេចក្តីសុខដោយ មេត្តា ឱ្យសេចក្តីស្រឡាញ់និងប្រាថ្នាល្អចំពោះមិត្ត ករុណា ជួយមិត្តមិនសង្ឃឹមការតបស្នង មុទិតា ត្រេកអរតាមនៅពេលអ្នកដទៃបានសម្រេច ឧបេក្ខា មានការសម្លឹងជាកណ្តាលដោយស្មារតី នៅពេលជួយអ្វីគេមិនបាន ព្រោះសត្វលោករមែងប្រព្រឹត្តទៅតាមកម្ម ម្យ៉ាងទៀត កូនកុំញុះញង់ឱ្យគេទាស់ទែងគ្នាជាដាច់ខាត ។

## ព្រហ្មវិហារជាជម្រកដ៏ប្រសើររបស់ចិត្ត

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

កូនសាកសង្កេតមើលនឹងឃើញថា ៖ សេចក្តីទុក្ខវានឹងមកជួបយើងដោយមិនដឹងខ្លួនជាមុន ព្រោះដូច្នេះយើងត្រៀមប្រឈមមុខជាមួយនឹងវា ដោយការរៀនឱ្យស្គាល់សេចក្តីទុក្ខ កាលបើសេចក្តីទុក្ខមកដល់ត្រូវចេះកែខៃស្ថាន-ការណ៍ឱ្យបានល្អឡើង ហើយត្រូវគិតថា វានឹងកន្លងទៅ ។

កូនមាសឪពុកត្រូវប្រាប់ខ្លួនឯងថា ៖ យើងកើតមកដើម្បីដោះស្រាយនូវសេចក្តីទុក្ខ បើកូនធ្វើគ្រប់យ៉ាងដោយសុចរិត ប្រាថ្នាល្អដល់អ្នកដទៃហើយ កូនមិនបន្ទោសខ្លួនឯងឡើយ ។

**ការរស់នៅនៃតណ្ហាឈ្លះរស់ទុក្ខទាំងពួង**



# កូនមាសឪពុក

ចំណង់ ជាធម្មជាតិដែលកើតឡើងតាមគ្រា ចំណង់ធ្វើឱ្យកូនកើតទុក្ខ ។

បើកូនចង់ច្រើន កូនមានទុក្ខច្រើន

បើកូនចង់តិច កូនមានទុក្ខតិច

បើកូនមិនចង់ទេ កូនក៏មិនមានទុក្ខដែរ ប៉ុន្តែបើកូនចង់យ៉ាងត្រឹមត្រូវ សេចក្តីចម្រើននឹងមានដល់កូន ។

ចង់ស្វែងរកចំណេះមកដាក់ខ្លួន ចង់កសាងខ្លួនឱ្យបានជាមនុស្សល្អ... គឺជាចំណង់យ៉ាងត្រឹមត្រូវ ប៉ុន្តែឪសូមផ្តាំ កូនត្រូវមានចិត្តត្រជាក់ ហើយគិតឱ្យល្អ ។

**ការចេះដឹងក្នុងហេតុផលនាំឱ្យមានចិត្តត្រជាក់**

# កូនមាសឪពុក

ពេលកូនយល់ព្រម ឬសន្យាជាមួយអ្នកណា កូនត្រូវគិតឱ្យស្រួលបួល កុំរសេមរសាម កូនត្រូវឱ្យច្បាស់លាស់ក្នុងការងារសុចរិត ហើយត្រូវប្រព្រឹត្តតាមសន្យា កូនកុំជាមនុស្សឡេះឡោះឡើយ ។

បើកូនធ្វើខុស កូនត្រូវចេះសូមអភ័យទោស រួចហើយកូនត្រូវតែប្រឹងប្រែងកុំឱ្យខុសលើកក្រោយទៀត ។

**កំហុសទុកជាគ្រូ តែកុំខុសដដែលៗ**



# កូនមាសឪពុក

កូនចូរចាំទុកថា :

ការអនុគ្រោះដ៏ក្រៃលែងជាទីបំផុត គឺការឱ្យអភ័យ រីឯការទទួលដែលសមគួរបំផុតសម្រាប់មនុស្សយើង គឺការទទួលធម្មទានដើម្បីយកមកបដិបត្តិ ។

**ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌**





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

សេចក្ដីអត់ធន់ចំពោះការសិក្សារកការចេះដឹង ប្រសើរជាងសេចក្ដីអត់ធន់ចំពោះភាពទ័លក្រ ។

កូនរបស់ឪចូរអត់ធន់ និង ប្រឹងប្រែងតស៊ូក្នុងការសិក្សារៀនសូត្រ ខំរៀនដឹងរបស់ផ្សេងៗនៅជុំវិញជីវិត ហើយនាំយកការចេះដឹងមកប្រកបការងារ ដើម្បីកុំឱ្យជួបប្រទះនូវភាពក្រលំបាក និងដែលជាការសំខាន់ណាស់ទៅទៀតនោះ គឺកូនអាចនឹងជួយអ្នកដទៃបាន ។

**កើតមកជាមនុស្សត្រូវកសាងសមត្ថភាព**



## កូនមាសឪពុក

វិធីដែលនឹងធ្វើឱ្យកូនបានជាមនុស្សឆ្លាត និងចេះដឹងសព្វគ្រប់នោះ មិនជាការលំបាកឡើយ គឺគ្រាន់តែកូនអានសៀវភៅរាល់ៗថ្ងៃ ហើយនៅពេលអាននោះកូនត្រូវមានចិត្តតាំងមាំផង ។

ការអានសៀវភៅជាអង្គប្រកបមួយខាងក្រៅ នៅមានអង្គប្រកបមួយទៀតដែលជាខាងក្នុង គឺយោនិសោមនសិការ បានដល់ការពូកែគិតក្នុងហេតុផល អង្គប្រកបទាំងពីរនេះនាំឱ្យបានចម្រើនបញ្ញា ។

**ចំណេះដឹងមានប្រយោជន៍ណាស់**
**ត្រូវខំប្រឹងប្រែងស្វែងរកយកមកដាក់ខ្លួន**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនចូរចាំទុកថា : សេចក្តីទុក្ខនោះឯង វាខ្លាចស្នាមញញឹមណាស់ គ្រាន់តែកូនញញឹមតែបន្តិចប៉ុណ្ណោះ សេចក្តីទុក្ខក៏គេចខ្លួនបាត់ទៅហើយ ។

តើកូនដឹងទេថា : សេចក្តីទុក្ខនោះវាចូលចិត្តអ្វី? គឺសេចក្តីទុក្ខចូលចិត្តមនុស្សណា ដែលសម្លឹងមើលលោកនេះក្នុងផ្នែកអាក្រក់ ដូច្នេះ កូនត្រូវចេះសម្លឹងមើលលោកនេះក្នុងផ្នែកល្អ ផ្នែកល្អបំផុតក្នុងលោកគឺសេចក្តីពិត ។

### សេចក្តីពិតមានរសជាតិល្អជាងរសទាំងពួង



## កូនមាសឪពុក

ពេលវេលាមិនធ្លាប់នៅស្ងៀមឡើយ កូនឪក៏ដូចគ្នា កុំបញ្ឈប់ការព្យាយាមឱ្យសោះ ព្រោះបើកូនឈប់ព្យាយាមពេលណា ជីវិតកូនក៏ដូចជាស្លាប់នៅពេលនោះដែរ ប្រៀបដូចជានាឡិកាដែលអស់ថ្ម វារមែងងាប់គឺឈប់ដើរអ៊ីចឹង-ឯង សូមកូនឪកុំស្លាប់ទាំងរស់ឱ្យសោះ។

### ព្យាយាមនាំឱ្យឆ្លងរួចពីអន្លង់ទុក្ខ

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

បើកូនរង់ចាំនូវអ្វីមួយ កូនត្រូវមានចិត្តត្រជាក់ជាប្រក្រតី កូនត្រូវជាមនុស្សចេះអត់ធន់ រង់ចាំបានដោយមិនអន្ទះសា ។

មិនមានមនុស្សណាក្នុងលោកនេះ ដែលមិនធ្លាប់រង់ចាំនោះឡើយ ព្រោះការរង់ចាំជាសន្តានចិត្តរបស់មនុស្សគ្រប់គ្នា តែសូមឱ្យកូនពូកែក្នុងការរង់ចាំ កូនត្រូវរករបស់ណាដែលមានប្រយោជន៍ដល់ជីវិត ធ្វើកំដរក្នុងរវាងការរង់ចាំនោះទៅ ដូចជាការអានសៀវភៅ ឬការសរសេរអត្ថបទកំណាព្យជាដើម ។

**កុំទំនេរក្នុងកិច្ចការ ព្រោះថាវេលាមិនសម្បូណ៌**



# កូនមាសឪពុក

ចូរកូនដឹងទុកជាមុនចុះថា របស់៤យ៉ាង ជារបស់សូមបានដោយលំបាក ជារបស់ដែលមិនងាយសូមបានតាមបំណងឡើយ :

១.សូមមាសប្រាក់ទ្រព្យសម្បត្តិ

២.សូមយស និងបរិវារ

៣.សូមការរស់នៅអស់កាលយូរ

៤.ក្រោយពីស្លាប់សូមឱ្យបានកាន់សុគតិភព ។

ទាំង៤នេះ កូនមាសឪពុកមិនត្រូវសូមពីអ្នកណាឡើយ ត្រូវតែធ្វើយកដោយខ្លួនឯង ។

**អ្វីៗក្នុងលោករមែងកើតអំពីហេតុ**

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

កូនចូរចាំទុកថា គ្រប់យ៉ាងកើតពីការធ្វើរបស់យើង បើកូនធ្វើល្អ កូននឹងបានទទួលផលល្អ បើកូនធ្វើមិនល្អទេ កូនក៏នឹងបានទទួលនូវផលមិនល្អដែរ ។

ពាក្យថា «ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» នៅតែត្រឹមត្រូវ និងពិសោធបានគ្រប់ពេលវេលា ។

**សត្វលោករមែងប្រព្រឹត្តទៅតាមកម្ម**



# កូនមាសឪពុក

ឪពុកធ្លាប់ចាញ់អ្នកដទៃ ប៉ុន្តែឪពុកមិនធ្លាប់រួញរាថយក្រោយទេ កូនមាសឪពុកក៏ដូចគ្នាដែរ ទោះបីចាញ់ក៏កុំរួញរាថយក្រោយឡើយ ហើយកូនឪនឹងបានឈ្នះ កាលដែលកូនបានឈ្នះ ចូរកូនកុំមើលងាយអ្នកចាញ់ឱ្យសោះ ព្រោះការមើលងាយជាចំណុចខ្សោយរបស់អ្នកឈ្នះ ។

ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា «អ្នកឈ្នះតែងប្រទះនូវពៀរ អ្នកចាញ់រមែងដេកជាទុក្ខ» ដូច្នេះចូរកូនចាំទុកថា មិនមានការតស៊ូណា ឱ្យប្រសើរជាងការតស៊ូយកឈ្នះចិត្តអាក្រក់របស់ខ្លួនឯងឡើយ ។

**សុខដទៃក្រៅពីសេចក្ដីស្ងប់មិនមានឡើយ**

# កូនមាសឪពុក

តើកូនមាននឹកឃើញសេចក្តីស្រឡាញ់របស់ម៉ែមក លើកូនដែរទេ ?

ម៉ែបានដាក់ទានឱ្យកូនជានិច្ចរាល់ថ្ងៃ

ម៉ែព្រមទទួលការលំបាកគ្រប់យ៉ាងជំនួសកូន

ម៉ែរង់ចាំបម្រើកូនជានិច្ចតាំងពីកូនកើតមក

ម៉ែបំបៅដោះកូន ថ្នមកូន ចិញ្ចឹមកូនជានិច្ច

ម៉ែភ័យញ័រខ្លួននៅពេលកូនឈឺម្តងៗ

ម៉ែជាគ្រូបង្រៀនកូនឱ្យចេះជុះនោម ចេះហូបចុក ចេះស្លៀកពាក់ បង្រៀនកូនឱ្យចេះអង្គុយ ចេះឈរ ចេះដើរ ចេះនិយាយ ...

ម៉ែជាគ្រូបង្វឹកគ្រប់យ៉ាងតាំងពីកូនកើតមក

ម៉ែទិញរបស់ឱ្យកូនលេង ទិញនំឱ្យកូនញ៉ាំ



ម៉ែជួយរៀបចំឧបករណ៍សិក្សាឱ្យកូន

ម៉ែជាធនាគារបើកប្រាក់ឱ្យកូនគ្រប់ពេល

ម៉ែជួយរៀបចំឱ្យកូនបានសុខស្រួលគ្រប់យ៉ាង

ម៉ែបានអប់រំកូនឱ្យមានកិរិយាមារយាទល្អ

ម៉ែបានទូន្មានកូនគ្រប់យ៉ាងចំពោះកិច្ចការប្រចាំថ្ងៃ

ម៉ែព្យាយាមដាស់កូនឱ្យក្រោករៀងរាល់ព្រឹក

ម៉ែប្រាប់ឱ្យកូនងូតទឹក ដុសក្អែលឱ្យកូន

ម៉ែសិតសក់ឱ្យកូន តែងខ្លួនឱ្យកូន

ម៉ែដឹកនាំឱ្យកូនចេះសុភាពរាបសា

ម៉ែដាស់តឿនកូនកុំឱ្យនិយាយអាក្រក់

ម៉ែរំលឹកកូនគ្រប់យ៉ាងនិងគ្រប់ពេល

។ល។ និង ។ល។

ម៉ែជាអាចារ្យ ម៉ែជាទេវតា ស្ថិតនៅក្នុងផ្ទះ
និងម៉ែជាព្រហ្ម ព្រមទាំងជាព្រះ កូនក្រាបសំពះ
ឈ្នះអស់សត្រូវ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## កូនមាសឪពុក

កូនត្រូវចាំទុក : ចូរកូនកុំប្រព្រឹត្តខ្លួនជាមនុស្សអួតមាន ជីវិតយើងរស់នៅបានសុខមិនមែនព្រោះមានទេ តែយើងមានជីវិតរស់នៅជាប្រក្រតី ក្នុងសេចក្តីសុខទៅបានព្រោះមានការអត់ធន់ ស្មោះត្រង់ ហ្មត់ចត់មធ្យ័ត ព្យាយាមមិនតម្កើងខ្លួន និងជាមនុស្សកតញ្ញូ ។

**មនុស្សមិនមែនមានអាយុវែងព្រោះទ្រព្យឡើយ**



## កូនមាសឪពុក

កាលណាកូនឃើញអ្នកដទៃមានទ្រព្យជាងយើង ចូរកុំឥស្សាច្រណែននឹងគេ កូនចូរមើលអ្នកដែលក្រជាងយើងផង គឺមានច្រើនណាស់ ចូរកូនត្រេកអរជាមួយអ្នកដែលមានជាងយើង ។

ពេលណាកូនឃើញអ្នកដទៃក្រលំបាកជាងយើង កូនចូរមានមេត្តា កុំសម្លុតកំហែងអ្នកដែលក្រីក្រលំបាកនោះឡើយ កូនត្រូវជួយគេតាមដែលអាចជួយទៅបាន ។

មនុស្សល្អឬមិនល្អ មិនបានវាស់គ្នាដោយមាន ឬដោយក្រនោះទេ គឺត្រូវវាស់គ្នាដោយទឹកចិត្ត វាស់ដោយការប្រព្រឹត្ត ។

**ការសម្លឹងមើលលោកដោយត្រឹមត្រូវ**
**នាំមកនូវសេចក្តីសុខ**

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

ចូរកូនពិចារណានូវកំណាព្យនេះ :

រូបសល្អរាងគួរស្រឡាញ់ តែចាញ់ល្អចិត្តគំនិតជា
មិនយូរប៉ុន្នានរូបជរា ឯចិត្តល្អជាមិនចាស់ឡើយ។
កូនមាសឪពុកចូរកុំភ្លេច ធម៌ថ្លៃជាងពេជ្រនាំដល់ត្រើយ
មានរូបមានរោគឥតស្រាកស្បើយ កូនអើយព្រះធម៌មិនចេះឈឺ។
បើកូនរៀនធម៌អប់រំចិត្ត ប្រព្រឹត្តសុចរិតចិត្តកូនភ្លឺ
ជីវិតត្រូវស្លាប់រូបត្រូវឈឺ ប៉ុន្តែចិត្តភ្លឺមិនស្លាប់ទេ ។
ចិត្តភ្លឺ៧ខ្លាំងជាងសុរិយា ភ្លឺដោយបញ្ញាចិត្តទំនេរ
កើតចាស់ឈឺស្លាប់ព្រោះក្តីស្នេហ៍ ឯចិត្តទំនេរផុតទុក្ខហោង ។

**ចិត្តល្អមិនជរា ព្រះធម្មាមិនចេះឈឺ**
**ខាត់ចិត្តឱ្យបានភ្លឺ មានពន្លឺផុតក្តីស្លាប់។**



# កូនមាសឪពុក

ឪពុកម្តាយសប្បាយចិត្តណាស់ ដែលបានឃើញកូនប្រព្រឹត្តល្អ ប៉ុន្តែ ឪពុកម្តាយក៏ខូចចិត្តណាស់ដែរ ព្រោះតែការប្រព្រឹត្តមិនល្អរបស់កូន ។

ចូរកូនពុកកុំបណ្តោយឱ្យចំណង់ ដែលចង់មានចង់បាន និងចង់រស់ អូសទាញកូនទម្លាក់ជ្រោះនៃសេចក្តីវិនាសឡើយ ឪសូមឱ្យកូនមានសម្បជញ្ញៈកសាងខ្លួន ។

**មនុស្សគឺជាសត្វដ៏វិសេសអាចកសាងខ្លួន**
**ឱ្យបានជាទីគោរពនៃទេវតាទាំងឡាយ**

# កូនមាសឪពុក

បើកូនស្រឡាញ់ម៉ែឪ និងកាលកូនពិចារណាទៅហើយ បានដឹងថា ខ្លួនជាទីស្រឡាញ់នៃខ្លួនឯងដ៏ក្រៃលែងនោះ កូនត្រូវរក្សាខ្លួនឱ្យជាការរក្សាដ៏ល្អ ឪពុកសូមប្រគល់ពាក្យទាំងនេះដល់កូន :

១

កូនចូរចាំទុកថា : ការមិនតស៊ូក្នុងករណីខ្លះ គឺជាវីរភាពដ៏ធំធេង ក្រៃលែងជាងការតស៊ូយកស្លាប់យករស់ទៅទៀត ។

២

កូនចូរកុំរើសយកនូវរបស់ដែលពេញចិត្ត ដោយអំណាចនៃចំណង់របស់ខ្លួន តែកូនត្រូវរើសយកនូវរបស់នោះៗដោយសតិបញ្ញា កូនត្រូវពិចារណាដល់ប្រយោជន៍ និងទោសនៃរបស់នោះឯងមុននឹងសម្រេចចិត្តថាយក ។



៣

កូនត្រូវកុំក្រោធខឹង ជាមួយនឹងមនុស្សដែលធ្វើមិនល្អឱ្យសោះ តាមពិត គេនោះក៏ចង់ល្អដែរ គ្រាន់តែគេមិនបានយល់ច្បាស់ថា អ្វីជាសេចក្ដីល្អ អ្វីជាសេចក្ដីអាក្រក់ឱ្យពិតប្រាកដប៉ុណ្ណោះ ។

៤

កូនត្រូវដឹងថា : ក្នុងលោកនេះកម្រករអ្នកដែលចេះត្រេកអរ និងពាក្យបន្ទោសណាស់ ដូច្នេះកូនកុំចូលចិត្តបន្ទោសអ្នកដទៃឡើយ ម្យ៉ាងទៀត បើកូនចង់តិះដៀលឱ្យអ្នកណា កូនត្រូវសម្លឹងមើលខ្លួនឯងជាមុន កុំឱ្យគេស្ដីបកមករកវិញ ។

៥

មាសប្រាក់ដែលកូនមាន បើចាយណាស់រឹតតែអស់ណាស់ ចំណែកវិជ្ជាវិញនោះ រឹតតែប្រើរឹតតែចម្រើន ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

៦

កូនចូរចាំទុកថា : មាសប្រាក់ជារបស់ក្រៅខ្លួន មាតាបិតាសប្បាយចិត្តព្រោះកូនចេះស្រឡាញ់គ្នារវាងបងប្អូន ។

៧

កូនចូរធ្វើគ្រប់យ៉ាងដោយសុចរិត កាលបើមានសុចរិតចិត្តរមែងស្អាត តែបើមាននូវទុច្ចរិតវិញចិត្តរមែងសៅហ្មង ។

៨

ទ្រព្យសម្បត្តិមិនមែនជារបស់ចាំបាច់ ក្នុងការដែលឪពុកម្តាយប្រគល់ឱ្យកូននោះទេ ចំណេះដឹងនិងការប្រព្រឹត្តល្អតែប៉ុណ្ណោះ ដែលគួរជាទីបំផុតក្នុងការដែលម៉ែឪត្រូវប្រគល់ឱ្យដល់កូនសម្លាញ់ ។

៩

ចុងបំផុតផ្លូវនៃសេចក្តីលោភលន់ មិនចេះគ្រប់គ្រាន់ គឺសេចក្តីទុក្ខ ។



១០

អ្នកដែលមិនធ្លាប់ឱ្យអភ័យដល់អ្នកដទៃ គឺជាអ្នកដែលទន់ខ្សោយដោយគុណធម៌ ការឱ្យអភ័យដល់សត្រូវ គឺជាការសាងមិត្ត រមែងរុងរឿងដូចជាព្រះមហោសថ ។

១១

បើអ្នកដទៃបោកបញ្ឆោត យើងអាចដឹងងាយ និងដោះស្រាយបានងាយជាង តែបើកូនបញ្ឆោតខ្លួនឯងវិញ គឺដឹងបានដោយលំបាក ដោះស្រាយក៏បានដោយលំបាកដែរ។

១២

កូនគួរចាំនូវអ្វីដែលគួរចាំ គួរភ្លេចនូវអ្វីដែលគួរភ្លេច គួរធ្វើនូវអ្វីដែលគួរធ្វើ និងត្រូវដឹងថា ការងារណាដែលគួរធ្វើមុន ការងារណាដែលគួរធ្វើក្រោយ ។

១៣

ប្រសិនបើ កូនដួលព្រោះការឈានដើរទៅខាងមុខ វាប្រសើរជាងកូននៅឈរទ្រឹងមួយកន្លែង ព្រោះបើកូនឈរទ្រឹងមួយកន្លែង កូននឹងដួលនៅត្រង់កន្លែងនោះ

Document Produced by deskPDF Unregistered :: http://www.docudesk.com

ហើយកូននឹងមានឈ្មោះថាជាមនុស្សកំសាក ... កូនត្រូវព្យាយាមក្នុងកិច្ចការដែលជាតួនាទី កូនត្រូវចាំទុកថា ជីវិតកើតមកដើម្បីទ្រាំ គឺការអត់ធន់តស៊ូ ។

១៤

មិនថាមនុស្ស ឬសត្វតិរច្ឆាន សុទ្ធតែត្រូវការស្តាប់ពាក្យផ្អែមល្ហែម ពាក្យទន់ភ្លន់ កូនមាសឪពុកក៏ដូចគ្នា គួរនិយាយពាក្យទន់ភ្លន់ ផ្អែមល្ហែមដល់អ្នកដទៃ កាលបើកូននិយាយពាក្យពីរោះចំពោះអ្នកដទៃ កូននឹងបានទទួលនូវពាក្យពីរោះពីអ្នកដទៃវិញ កាលបើកូនទន់ភ្លន់ដាក់អ្នកដទៃ អ្នកដទៃក៏ទន់ភ្លន់ដាក់កូនវិញដែរ ។

១៥

ភ្លេចអ្វីអាចភ្លេចបាន តែកុំភ្លេចខ្លួន ខូចអ្វីដទៃក៏ខូចចុះ ! តែត្រូវប្រយ័ត្នកុំឱ្យខ្លួនជាមនុស្សខូច ។

១៦

ការធ្វើរបស់កូនពេលខ្លះ មិនទាំងពេញចិត្តខ្លួនឯងផង តើនឹងឱ្យអ្នកដទៃធ្វើនូវអ្វីៗត្រូវចិត្តរបស់កូនបានរហូត



នោះយ៉ាងដូចម្តេចទៅ កាលកូនគិតឃើញដូច្នេះហើយ កូននឹងមិនខឹងក្រោធជាមួយអ្នកដទៃឡើយ ។

១៧

កូនមាសឪពុក ធម្មជាតិមិនដែលឱ្យអភ័យដល់អ្នកណាឡើយ អ្នកណាធ្វើយ៉ាងណាត្រូវបានទទួលយ៉ាងនោះ តែធម្មជាតិបានឱ្យឱកាសដល់មនុស្សយើងគ្រប់គ្នា គ្រាន់តែថា ដោយច្រើនមនុស្សយើងមិនចេះទទួលយកនូវឱកាសនោះមកកសាងខ្លួន ឬយកមកកែខ្លួនប៉ុណ្ណោះឯង ។

១៨

កូនចោលអ្វីផ្សេងបាន តែកូនកុំបោះបង់ខ្លួនឯងចោលឱ្យសោះ ព្រោះក្នុងលោកនេះ មិនមានអ្នកណាជាទីពឹងរបស់កូនក្រៅអំពីខ្លួនកូនឯងឡើយ ។

១៩

កូនត្រូវដឹងថា : អ្នកក្លាហាន គឺអ្នកដែលអាចបង្គាប់ខ្លួនឯងបាន ជាចៅហ្វាយនាយលើខ្លួនឯង មិនមែនមានតណ្ហា ឬសេចក្តីក្រោធខឹងជាចៅហ្វាយនាយឡើយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

២០

កូនកើតមកជាមនុស្សហើយ ត្រូវព្យាយាមបំពេញសេចក្ដីល្អឱ្យខ្លាំងក្លាជាទីបំផុត ព្រោះកូនមិនងាយបានជួបនូវឱកាសល្អដូចនេះឡើយ ។

កូនដាំដំណាំបម្រុងឫស តែបើដាំមនុស្សបម្រុងសីល ចង់ឆ្លងចាកទុក្ខត្រូវកុំខ្ជិល ខូចខិលដឹងខុសត្រូវកែខ្លួន។

២១

មានតែមនុស្សដែលចេះប្រយ័ត្នប៉ុណ្ណោះឯង ដែលអាចរក្សាខ្លួនទុកឱ្យប្រពៃបាន កូនឪពុកត្រូវរក្សាខ្លួនដោយប្រយ័ត្នប្រយែងជាទីបំផុត ព្រោះមិនមានអ្វីដែលត្រូវរក្សាឱ្យក្រៃលែងជាងការរក្សាខ្លួននេះឡើយ ។

២២

កូនត្រូវដឹងថា : ក្នុងលោកនេះរមែងមានរឿងដែលសម្រាប់ឱ្យយើងមានសេចក្ដីអត់ធន់ កាលបើកូនអត់ធន់បាន កូននឹងសម្រេចផលល្អប្រៀបដូចថ្នាំគ្រុន នៅពេលញុាំវារមែងល្វីង ប៉ុន្តែផលរបស់វាគឺត្រជាក់ខ្លួនបាត់គ្រុន។



២៣

ភ្លេចអ្វីភ្លេចបាន តែបើភ្លេចប្រាណ ឈានធ្លាក់រណ្ដៅ
បើបានជាភ្លាត់ មិនទាន់ធ្លាក់ជ្រៅ ប្រឹងឡើងណាពៅ
កុំនៅនាំជ្រុល ។
ខូចអ្វីមិនគ្រោះ តែបើខូចឈ្មោះ មិនងាយជួសជុល
កូនត្រូវប្រយ័ត្ន កុំងប់ងមុល កាមជាគ្រឿងពុល
ខូចអស់ទាំងខ្លួន ។
ខូចខ្លួនខូចឈ្មោះ ខូចនេះពេញគ្រោះ រស់លែងស៊ប់សួន
តែទោះយ៉ាងណា កុំឱ្យខូចផ្នួន ត្រូវប្រឹងកែខ្លួន
កុំចោលអាត្មា ។
ចោលអ្វីចោលបាន តែកុំចោលប្រាណ ក្នុងវដ្តសង្សារ
ព្រោះក្នុងលោកនេះ ឥតមាននរណា ជួយស្រង់អាត្មា
ក្រៅពីខ្លួនឡើយ។
កូនត្រូវរក្សា ការពារអាត្មា ឱ្យបានដល់ត្រើយ
ដោយការប្រយ័ត្ន និងមិនកន្តើយ ប្រយ័ត្នហ្នឹងហើយ
ជាព្រះក្នុងខ្លួន ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ប្រយ័ត្នជាម្ដាយ ញាំងគុណទាំងឡាយ ឱ្យកើតមាំមួន
អត់ធន់ជាឪ រក្សាគ្រងស្ងួន គុណធម៌ក្នុងខ្លួន
ដូចខែខាងខ្នើត ។
ខន្តីដូចថ្នាំ លេបជាប្រចាំ រសជាតិល្វីងឆើត
លំបាកទ្រាំណាស់ លុះដល់ផលកើត រសជាតិល្វីងឆើត
មានគុណគាប់ហោង។

២៤

បុរាណបានពោលថា : ចោរលួចប្លន់ទ្រព្យសម្បត្តិ មិនស្មើនឹងភ្លើងឆេះផ្ទះ ភ្លើងឆេះផ្ទះមិនស្មើនឹងចាញ់ល្បែងភ្នាល់ ចាញ់ល្បែងភ្នាល់មិនស្មើនឹងជាប់គ្រឿងញៀន ។

ចោរប្លន់នៅសល់ផ្ទះ អស់ប្រាក់មាសមិនជាអ្វី
ឆេះផ្ទះនៅសល់ដី អត់បាយឆីដីលក់បាន ។
ចាញ់ល្បែងនៅជីវិត បើចេះគិតវិលវិញថ្កាន
ញៀនថ្នាំប្រចាំប្រាណ កែលែងបានស្លាប់ទាំងរស់។



# កូនមាសឪពុក
# ត្រូវជាមនុស្សដូចតទៅ

☆ កូនស្រីឪ ត្រូវជាមនុស្ស មិនរឹងត្អឹង
តែបើរឹង ត្រូវរឹងប៉ឹង ប្រឹងសិក្សា
កូនប្រុសឪ ត្រូវជាមនុស្ស មានប្រាជ្ញា
ព្រះផ្ដាំថា កុំស្នេហា ស្រាស្រីល្បែង។
☆ កូនស្រីឪ ត្រូវជាមនុស្ស មិនជាប់នុយ
កុំស្នេហ៍លុយ ស្អុយកេរ្ដិ៍ឈ្មោះ រស់ដូចផ្សែង
កូនស្រីឪ ត្រូវជាមនុស្ស ចេះខ្លាចក្រែង
ព្រះសម្ដែង ឱ្យទម្លាប់ ជាប់សីលវិញ ។
☆ កូនប្រុសឪ ត្រូវជាមនុស្ស ចេះស្មោះត្រង់
កុំតាមចង់ ក្រែងមិនសុខ ទុក្ខម្នោម្នេញ
កូនប្រុសឪ ត្រូវជាមនុស្ស តាមចេះវិញ
ប្រឹងបំពេញ ធម៌សន្ដោស ប្រោសមេត្តា ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

★ កូនស្រីឪ ត្រូវជាមនុស្ស មិនប្រមាទ
ជាស្រីឆ្លាត ចេះប្រមើល មើលកិច្ចការ
កូនស្រីឪ ត្រូវជាមនុស្ស ទន់ចរិយា
តែយ៉ាងណា សូមស្រីម៉ុម កុំទន់ខ្សោយ។

★ កូនប្រុសឪ ត្រូវជាមនុស្ស ចេះអត់ធន់
ការស្រោលធ្ងន់ កុំទម្រន់ ទន់បណ្តោយ
កូនប្រុសឪ ត្រូវជាមនុស្ស មិនថយក្រោយ
កុំចាំឱ្យ មនុស្សស្រីច្រាន បានទៅមុខ ។

★ កូនស្រីឪ ត្រូវជាមនុស្ស មិនឡេះឡោះ
ពាក្យពីរោះ មានរបៀប រៀបទំនុក
កូនស្រីឪ ត្រូវជាមនុស្ស រក្សាសុខ
បើខ្លាចទុក្ខ កុំជាមនុស្ស ទ្រុស្តសីលធម៌ ។

★ កូនប្រុសឪ ត្រូវជាមនុស្ស ចេះស្គាល់ខ្លួន
ចិត្តមាំមួន មិនអំនួត អួតខ្លារខ្ញ័រ
កូនប្រុសឪ ត្រូវជាមនុស្ស មិនញាប់ញ័រ
ជួបលោកធម៌ ត្រូវពិចារណ៍ ថាមិនទៀង ។

-៩៩-

★ កូនស្រីឪ ត្រូវជាមនុស្ស ចេះដឹងគុណ
ជាដើមទុន នៃជីវិត ពិតជាស្បៀង
កូនស្រីឪ ត្រូវជាមនុស្ស មិនលំអៀង
សម្តីទៀង ពិតប្រាកដ មាត់ក្រអូប ។

★ កូនប្រុសឪ ត្រូវជាមនុស្ស ចេះចាប់ផ្តើម
កុំច្បិចច្បើម ត្រូវប្រឹងប្រែង ក្រែងខ្វះហូប
កូនប្រុសឪ ត្រូវជាមនុស្ស មិនចេះល្មោភ
តែបើទ្រោប ទ្រោលដល់ខ្ជិល វិលបញ្ញា ។

★ កូនស្រីឪ ត្រូវជាមនុស្ស មិនច្រណែន
រៀបបែបផែន ជាមង្គល ដល់គ្រួសារ
កូនស្រីឪ ត្រូវជាមនុស្ស មានមេត្តា
មិនឥស្សា ក្នុងជីវិត ពិតជាស្ងប់ ។

★ កូនប្រុសឪ ត្រូវជាមនុស្ស ដឹងប្រមាណ
ក្នុងខ្លួនប្រាណ រាល់យប់ថ្ងៃ លៃឱ្យគាប់
កូនប្រុសឪ ត្រូវជាមនុស្ស មិនអភ័ព្វ
មិនត្រូវជាប់ គ្រឿងញៀនញ៉ាម កាមគុណ៥ ។

-១០០-

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តមិត្តភក្តិ
កុំជំពាក់ ទ្រព្យបំណុល បុលបញ្ចាំ
កុំរ៉ាប់រង ធានាទ្រព្យ ជាប់គ្រោះកម្ម
ឱសូមផ្តាំ កម្មវេរា ជាគ្រោះកាច។

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តសីលា
កុំគិតថា សីលនេះណា ខ្លាកំណាច
តាមពិតសីល ជាទេវតា ក្លាអង់អាច
មានអំណាច អាចប្រហារ ខ្លាកិលេស ។

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តមាតា
ស្រីនេះណា ជាព្រះព្រហ្ម កុំប្រហែស
តែព្រហើន ហ៊ានឃោរឃៅ ត្រូវភ្លើងឆេះ
ជាតិអ្នកចេះ ត្រិះរិះដឹង ប្រឹងបូជា ។

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តបិតា
ត្រូវដឹងថា ប្រុសនេះណា ជាព្រហ្មា
បានសុខហើយ ក្នុងជំរំ ព្រហ្មវិហារ
ត្រូវម្មីម្នា ភ្ជាររលឹក នឹកតបគុណ ។

-១០១-

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តព្រះពុទ្ធ
ត្រូវលំអុត កាយវាចា ប្រាថ្នាបុណ្យ
កូនមានទាន សីលភាវនា ជាដើមទុន
ផុតទារុណ ចាកអបាយ ឆ្ងាយពីទុក្ខ ។

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តព្រះធម៌
កុំជាប់ជ័រ នៃកាមគុណ ស៊ុនក្នុងគុក
ប្រឹងដើរតាម ស្នាមព្រះបាទ ព្រះជាន់ទុក
កុំសម្រុក ធ្វើដំណើរ ដើរផ្លូវមារ ។

☆ កូនប្រុសស្រី កុំជាមនុស្ស ទ្រុស្តព្រះសង្ឃ
ត្រូវនឹកត្រង់ អង្គសាវ័ក ព្រះភគវ៉ា
ទ្រង់សាសនា ព្រះជិនស្រី ល្បីខ្ចរខ្ចារ
ក្រងធម្មា ជាបិដក វិ. សុ. អ. ។

-កូនមាសឪពុកទាំងឡាយអើយ ព្រះធម៌មានហើយកុំធ្វើខ្ជាក់
ប្រឹងអានប្រឹងគិតឱ្យប្រចក្ស ខណៈដ៏ល្អកុំកន្លង ។
-ថ្ងៃ១៥កើតខែពិសាខ ជាថ្ងៃសម្រាកធ្វើបុណ្យឆ្លង
ព្រះពុទ្ធទ្រង់កើតជាចម្បង ចម្លងសត្វលោកផុតភពបី ។

-១០២-



Document Produced by deskPDF Unregistered :: http://www.docudesk.com

-ថ្ងៃ១៥កើតខែអាសាឍ  កូនឪត្រូវឆ្លាតយល់សេចក្តី
ថ្ងៃនេះជាថ្ងៃព្រះជិនស្រី  ចាប់ផ្តើមពោលស្តីត្រាស់ទេសនា។
-ជាថ្ងៃកំណើតនៃព្រះធម៌  ស្តាប់ហើយតាំងគភ៌ដ៏ថ្លៃថ្លា
ដល់ពេលប្រសូតបានសោតា  ផុតចាកទុក្ខាក្នុងអបាយ ។
-ថ្ងៃដែលព្រះសង្ឃមានកំណើត ថ្ងៃ១៥កើតមិនមែនឆ្ងាយ
គឺថ្ងៃតែមួយដែលធម្មកាយ  ចាប់ផ្តើមផ្សព្វផ្សាយដោយព្រះពុទ្ធ។
-ព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ  កូនត្រូវឱនអង្គយ៉ាងលំអុត
គោរពបូជាដោយមោះមុត  ប្រសើរបំផុតត្រង់ចិត្តស្អាត។
-ថ្ងៃ១៥កើតមាឃបូជា  អង្គព្រះភគវាទ្រង់ឱវាទ
ប្រាប់បេះដូងធម៌ក្នុងសន្និបាត  គឺជាឱវាទបាតិមោក្ខ ។
-ពិសាខ.អាសាឍ.មាឃបូជា  កូនឪគ្រប់គ្នាប្រញាប់ក្រោក
ទៅវត្តស្តាប់ធម៌បាតិមោក្ខ  កុំឱ្យចាញ់បោកមារក្នុងខ្លួន។
-រៀបចំភ្ញីផ្កាគ្រឿងបូជា  សំពះវន្ទាឱ្យស៊ប់សួន
ធ្វើទានកាន់សីលឱ្យខ្ជាប់ខ្ជួន  គំនុំគុំគួនកុំបីមាន ។

✍📖✍



# កូនមាសឪពុក

## សម្បត្តិឱវាទកាត់ថ្លៃមិនបានឡើយ

ទ្រព្យសម្បត្តិម្យ៉ាង  ដែលឪពុកម្តាយប្រគល់ឱ្យដល់កូន  គឺការអប់រំទូន្មានប្រៀនប្រដៅ  ដែលជាការបណ្តុះបណ្តាលនូវឧបនិស្ស័យល្អឱ្យកើតមានក្នុងខ្លួនរបស់កូន ។

ការអប់រំទូន្មាន  ជាសម្បត្តិមហាសាល  មិនមានថ្ងៃដែលនឹងត្រូវចាយអស់ឡើយ  ឱ្យតែកូនចេះនឹករលឹកដល់ពាក្យទូន្មានទាំងអស់នោះ  ហើយមានការប្រព្រឹត្តតាមដោយត្រឹមត្រូវ ។

ទ្រព្យសម្បត្តិមាសប្រាក់  មិនអាចយកទៅទិញនូវសេចក្តីល្អមកទុកដាក់ក្នុងខ្លួនបានឡើយ  ប៉ុន្តែសេចក្តីល្អដែលកើតមាននៅក្នុងខ្លួនរបស់កូន  គឺព្រោះអាស្រ័យការអប់រំ  ការបង្ហឹកបង្ហាត់និងបង្ហាញប្រាប់  ដោយសេចក្តីស្រឡាញ់  និងដោយសេចក្តីព្យាយាម  របស់មាតាបិតាដែលជាគ្រូដើមមុនគេបង្អស់របស់កូនហ្នឹងឯង ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

កាលបើកូនមាសឪពុក បានយល់ដឹងដល់ការអប់រំ ថាជាសម្បត្តិដ៏ប្រសើរក្រៃលែងហើយនោះ កូនត្រូវមានចិត្តរីករាយជានិច្ច ក្នុងការទទួលយកនូវពាក្យទូន្មានប្រៀនប្រដៅទាំងឡាយ ។

កូនត្រូវចាំទុកថា : សម្បត្តិគឺការអប់រំទូន្មាន នឹងមានប្រយោជន៍ដល់កូនទៅបាននោះ វាអាស្រ័យនៅលើកូនខ្លួនឯងជាអ្នកបដិបត្តិ ។

ឪពុកម្តាយ បំពេញតួនាទីជាគ្រូដោយមិននឹករំពឹងរកតម្លៃនៃការតបស្នងអ្វីឡើយ ទោះបីមានសេចក្តីលំបាកយ៉ាងណាក៏ដោយ ក៏ម៉ែឪនៅតែមានការព្យាយាមជានិច្ចដែរ ទាំងអស់នេះព្រោះមកអំពីការទូន្មានរបស់ឪពុកម្តាយបានហូរចេញពីក្រអៅបេះដូងដ៏ស្មោះ ដែលពេញពោរទៅដោយទឹកចិត្តមេត្តា សេចក្តីស្រឡាញ់និងការអាណិតអាសូរចំពោះកូន ។

ទឹកចិត្តឪពុកម្តាយ ដែលស្រោចស្រពដណ្តប់លើកូនដោយអំណាចព្រហ្មវិហារ គឺ ស្រទន់ដូចមេឃស្រទំ ។

-១០៥-

ទ្រព្យវិជ្ជា ជាកំណប់ ទ្រព្យប្រពៃ
កូនឆ្លាតវៃ លៃយកទ្រព្យ កប់ក្នុងខ្លួន
ស្មើម៉ែឪ នៅជាមួយ ជួយថែថួន
ចិត្តមាំមួន ពួនផុតគ្រោះ រស់សេរី ។
ទ្រព្យចំណេះ ចេះគ្រប់យ៉ាង សាងប្រយោជន៍
មិនហិនហោច ដូចជាទ្រព្យ កប់ក្នុងដី
ទ្រព្យចំណេះ ឆេះភ្លឺព្រោង យោងប្រុសស្រី
ចូរឃ្លាតខ្ចី បីត្រកង ត្រងយកចេះ ។
បុព្វាចារ្យ សាស្តាដើម ផ្តើមពិសិដ្ឋ
នៅក្បៀកកិត ចិត្តទាក់ទិន មិនប្រហែស
បង្ហាត់កូន ស្ងួនពិសី ស្តីឱ្យចេះ
ផ្តល់ចំណេះ សំឡេះខ្មៅ ដៅរកកោះ ។

✍ មាតាបិតា ជាគ្រូអាចារ្យ ដំបូងបង្អស់
បង្ហាត់បង្ហាញ ដោយចិត្តស្ម័គ្រស្មោះ ឱ្យចេះចៅដោះ
បានរស់ដល់ធំ ។

-១០៦-



Document Produced by deskPDF Unregistered :: http://www.docudesk.com

បង្រៀនគ្រប់មុខ ជុះនោមហូបចុក ពុកចែវម៉ែអុំ
ម៉ែឪប្រឹងណាស់ ៉ាប់ខ្លួនជាខ្ញុំ ជួយឱ្យកូនធំ
នាំកូនរកត្រើយ ។
បង្ហាត់មារយាទ ប្រាប់ឱ្យស្គាល់ញាតិ យកគុណជាខ្នើយ
សុចរិតជាមុង ស្មោះត្រង់បក់ល្ហើយ ការមិនកន្តើយ
យកជាកន្ទេល ។
បង្ហាត់សម្តី ឱ្យកូនប្រុសស្រី និយាយដឹងពេល
ប្រដៅឱ្យក្រោក កុំនៅដេកទ្រេល ងូតទឹកដុសក្អែល
ម៉ែប្រាប់ទាំងអស់ ។

✍ ប្រាប់ឱ្យកូនធ្វើល្អ ស្លៀកពាក់សគឺចិត្តស្មោះ
ប្រដៅឥតមានខ្ចោះ ដូចគេច្រោះយកទឹកថ្លា ។
អប់រំគ្រើនរំលឹក ទោះល្ងាចព្រឹកឪទេសនា
ប្រាប់ឱ្យកូនឧស្សាហ៍ ធ្វើកិច្ចការជាកល្យាណ ។
សុចរិតថ្លៃជាងពេជ្រ កុំបំភ្លេចចោលខ្លួនប្រាណ
មនុស្សថ្លៃពន់ប្រមាណ កុំចោលប្រាណដូរយកប្រាក់។



ចោលប្រាណស្មើលក់ខ្លួន ឪពោលផ្តួនឱ្យប្រចក្ស
មនុស្សយើងថ្លៃជាងប្រាក់ ត្រូវទុកដាក់ខ្លួនឱ្យល្អ ។

✍ សុចរិតត្រឹមត្រូវនៅក្នុងខ្លួន ជាទីជ្រកពូនសត្វនិករ
មរតកម៉ែឪពន្លឺស ត្រាច់ចរតាមចិត្តជាប់រហូត។
ទ្រព្យដែលសំខាន់គឺឱវាទ អប់រំឱ្យឆ្លាតចិត្តកូនស្លូត
មរតកអស្ចារ្យធម៌ត្រៃកូដ កុំឱ្យរបូតពីខ្លួនឡើយ ។
សច្ចៈ ខន្តី កតញ្ញូ ធម៌បីជាគ្រូថៃកូនហើយ
កូនមាសឪពុកនឹងសះស្បើយ ជារោគដល់ត្រើយផុតទុក្ខា។
ចិត្តល្អក្រណាស់មិនអាចយក មាសប្រាក់ទៅរកទិញនៅផ្សារ
ប៉ុន្តែចិត្តល្អកើតដោយសារ មាតាបិតាប្រៀនប្រដៅ ។
ព្រោះហេតុដូច្នេះកូនមាសឆ្អិន កូនគិតឱ្យប៉ិនកុំឱ្យឆៅ
ឱវាទនិងប្រាក់ណាឆោមឆ្ងៅ តើកូនសំដៅមួយណាជាង។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

**បាបានំ អករណំ សុខំ**

វស្សា ឬ ប្រាំង ព្រះពុទ្ធ ទ្រង់ យាង
ត្រាច់ត្រាស់ប្រាប់ថាបាបត្រូវជៀសវាង
នោះទើប មិនឃ្វាង ពី សេចក្ដីសុខ ។

**សុខោ បុញ្ញស្ស ឧច្ចយោ**

កូន កុំ ធ្វើ ចោរ ហើយ កុំ សំកុក
ត្រូវ សន្សំ បុណ្យ ទើប កូន បាន សុខ
កុំចង់ ស្រណុក ព្រោះ ខ្ជិលឱ្យសោះ ។

**អព្យាបជ្ឈំ សុខំ លោកេ**

ក្នុង លោក ទំនេរ ពីការ ឈ្លោះ ទាស់
កូន រស់ បាន សុខ គ្រប់ គ្នា ទាំងអស់
ព្រោះ គ្មានទំនាស់ អស់ការ ព្យាបាទ។

**សុខំ យាវ ជរា សីលំ**

សីល មាន កម្លាំង ច្បាំង តាមក្បួនខ្នាត
ដណ្ដើម បាន សុខ កូន រស់ បាន ស្អាត
សុខ ឥត ភ្លាត់ ប្លាត ដរាប ដល់ចាស់ ។



**សុខា មត្តេយ្យតា លោកេ**

កូន គិត គ្នាន់គ្នេរ កុំ ឱ្យ មាន ខ្វះ
ប្រណិប័តន៍ មាតា ដោយ ដឹង គុណ ច្បាស់
បានបុណ្យច្រើនណាស់សុខសាន្តក្នុងលោក។

**អថោ បេត្តេយ្យតា សុខា**

ម្យ៉ាង ទៀត កូន ណា ប្រាថ្នា មាន ជោគ
ប្រណិប័តន៍ បិតា ថ្លៃថ្លា ប្រយោគ
មាន ភ័ព្វ បាន ភោគ ជា រោគ ជួប សុខ ។

**សុខា សទ្ធម្មទេសនា**

វាចា ថ្លៃថ្លា កាប់ ឆ្ការ ស្នាញ ស្នុគ
ការ សម្ដែង ធម៌ នាំ មក នូវ សុខ
បំផ្លាញ សម្បុក ខ្នាំង អវិជ្ជា ។

**សុខា សង្ឃស្ស សាមគ្គី**

ក្រុម ពួក សង្ឃ ជី មូល មីរ រួម គ្នា
មិន មាន បែក បាក់ ចាក់ រុក ខ្ចរខ្ចារ
នេះ ហើយ គឺជា ជំរំ សុខសាន្ត ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

**✍ ចិត្តំ គុត្តំ សុខាវហំ**

ព្យាយាម ដេញ ខ្នាំង ពី ចិត្តសន្តាន
គ្រប់គ្រងស្ងួនចិត្តដោយកម្មកល្យាណ
នាំសុខមកបានក្សេមក្សាន្តពេកក្រៃ ។

**✍ សុខោ បញ្ញាបដិលាភោ**

បានលាភ ថ្លៃថ្នូរ ជាង កែវចរណៃ
គឺ បាន បញ្ញា ភ្លឺ ច្បាស់ ជាង ថ្ងៃ
ឆ្លង កាត់ ភពត្រៃ ប្រពៃសុខសាន្ត។

**✍ សុខោ ពុទ្ធានមុប្បាទោ**

ព្រះពុទ្ធង្កូរ ពោរពេញ ក្លាហាន
កសាង បារមី សិរី ថ្កើងថ្កាន
រហូត ដល់បាន ត្រាស់ ជា ព្រះពុទ្ធ។

ព្រះពុទ្ធគ្រប់អង្គត្រាស់ដឹងក្នុងលោក
មានជ័យ មានជោគ ប្រាជ្ញា មោះមុត
ព្រះអង្គ ឈ្នះមារ នៅ ពេល ប្រយុទ្ធ
ដោយ សស្ត្រាវុធ មុតគ្មាន អ្វីដូច ។



ទ្រង់ត្រាស់ដឹងហើយនាំមកនូវសុខ
បំបែក សម្បុក ទិដ្ឋិ កំហូច
ដោយ ធម៌ទេសនា ភ្លឺថ្លា រុងរោចន៍
សុខ គ្មាន អ្វី ដូច គឺ ព្រះនិព្វាន ។

**✍ សុខា សទ្ធា បតិដ្ឋិតា**

កូន ស្តាប់ ទេសនា សាស្តា ទូន្មាន
បាន នូវ សទ្ធា ក្នុង ព្រះទ្រង់ញាណ
កូន បានជិះ យាន មាន ព្រះនាំផ្លូវ ។

សទ្ធាតាំង មាំ ក្នុង ចិត្តសន្តាន
កូន ពិតជា បាន ផុត រឿង អាស្រូវ
ជិះ យាន មាន សុខ សម្រុក ឆ្ពោះផ្លូវ
មគ្គល្អ ពេកកូវ ទៅ ទី ផុតស្លាប់ ។

សទ្ធា ជា ទ្រព្យ ថ្លៃថ្លា បវរ
ជាទ្រព្យត្រាច់ចរ ជាប់ក្នុងចិត្តស្រាប់
មាន គូ បញ្ញា ចាត់ការ ចំណាប់
ដល់ទីផុតស្លាប់អស់ការស្រេកឃ្លាន។

✍ **ហីនំ ធម្មំ ន សេវេយ្យ**

ទំនាស់ កាប់ចាក់ រំលោភ ឈ្លានពាន
ល្មើស គុណ ម៉ែ ឪ ទ្រុស្ត ព្រះទ្រង់ញាណ
ទ្រុស្ត នៅ ត្រង់ ហ៊ាន បំពាន សិក្ខា ។
ធម៌ ថោក ទាំងនេះ គឺ សែន **ហីនំ**
ស៊ី បាយ បោក ផ្ទាំង ខ្ទាំង នឹង សាសនា
កូន ឪ មិន ត្រូវ សេពគប់ ឡើយ ណា
បាលី ពោល ថា **ន សេវេយ្យ** ។
ធម៌ថោកមានច្រើនកើតកើនខ្លាំងណាស់
ទាំង ក្មេង ទាំង ចាស់ ប្រព្រឹត្ត ឥត អាក់
សេពគប់ ធម៌ ខ្មៅ ចាញ់ អំណាច ប្រាក់
ជាប់ ខ្នោះ ច្រវាក់ អន្ទាក់ កាមគុណ ។

✍ **បមាទេន ន សំវសេ**

កូន ត្រូវ វិះរេ គិត ទុក ជា មុន
រៀប ចំ ជីវិត ឱ្យ ផុត ទារុណ
បុណ្យ ជា ដើមទុន រួច ចាក ធម៌ ថោក។



កូន ឪ មិន ត្រូវ រស់ ដោយ ប្រមាទ
ត្រូវ ខំ សង្វាត កុំ ឱ្យ ចាញ់ បោក
តណ្ហា ក្នុង ចិត្ត បង្កើត ទុក្ខ សោក
កូន ព្យាយាម ក្រោក សម្លឹងធម៌ ពិត។
បើ កូន មិន ក្រោក ពិត ជា លំបាក
បញ្ញា ឥត ស្រាក ឆាកល្ខោន ជីវិត
កំព្រា ទីពឹង ក្នុង ភព ងងឹត
មោហៈ រួបរឹត ពិត ជា វង្វេង ។
ចូរ កូន សម្លាញ់ ស្តាប់ តាម ឪពុក
កូន កុំ ជាប់ គុក នៅ ក្នុង បទ ភ្លេង
ត្រូវ ចេះ ស្តាប់ ធម៌ កុំ ចេះ តែ លេង
ស្រីស្រាកែវពែង ជាល្បែងគ្រោះថ្នាក់។
ធម៌ សែន កំបាំង នៅ ក្នុង ជីវិត
រូប ពិត នាម ពិត ល្អិត ជា សច្ចៈ
សត្វ លោក ល្ងង់ ពិត ងងឹត ដូច ខ្វាក់
ឃើញត្រឹមតែប្រាក់ ស្ម័គ្រចិត្តធ្វើចោរ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

គិត ស្មាន បាន សុខ  ក្នុង អវិជ្ជា
យក ល្បង់ ធ្វើ គ្នា  មានះ ដូច តោ
ហ៊ានល្មើសនឹងច្បាប់ វ៉ាប់ខ្លួនធ្វើចោរ
សុខចិត្ត ជឿហោរ មិនជឿ ខ្លួនឯង។
កូនមាស ឪពុក កូនស្តាប់ឱ្យច្បាស់
ព្រះពុទ្ធបានត្រាស់ ហើយទ្រង់សម្តែង
ប្រកាស ធម៌ពិត ដោយឥតមានក្លែង
ត្រាស់ប្រាប់កន្លែង ដែលរួចចាកទុក្ខ។

**បញ្ញាឆ្លាតឈ្លាស  ក្នុងធម៌ទាំងឡាយ**
**សតិ  ក្នុងកាយ  យកជា  ប្រមុខ**
**កម្ចាត់  ភាពល្ងង់  ទម្លាយ  ទ្វារគុក**
**រួចផុត  ពីទុក្ខ  បានសុខ  ឧត្តម ។**

សរុប សេចក្តី ដែល ឪ បាន ប្រាប់
អត្ថន័យ  សារស័ព្ទ  ចាប់ យក ឱ្យ ចំ
គឺ ចង់ ឱ្យ កូន មាន ចិត្ត តាំងមាំ
ប្រឹងប្រែង  ខិតខំ  ទទួល និព្វាន ។



**ទទួលធម្មទាន  មានផលប្រសើរ**
**នាំកូនឱ្យដើរ  ក្នុងផ្លូវដែលស្អាត**
**គឺជាដំណើរ  តាមស្នាមព្រះបាទ**
**សម្បត្តិនិព្វាន  កាត់ថ្លៃមិនបាន ។**





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនមាសឪពុក

មាតាបិតាគឺជាទេវតាប្រចាំផ្ទះរបស់កូន ជាទេវតាថែរក្សាកូនទាំងយប់ទាំងថ្ងៃ ។

ពេលព្រលប់ ពេលយប់ ពេលអធ្រាត្រ មាតាបិតាកំពុងអស់កម្លាំងក្តី កំពុងងងុយក្តី កំពុងសម្រាន្តលក់ក្តី កំពុងក្តៅក្តី កំពុងរងាក្តី ទោះជាកំពុងឈឺខ្លួនឯងក្តី កាលបើកូនតូចស្រែកយំឡើង មាតាបិតារមែងស្ទុះស្ទា បើកំពុងលង់លក់ក៏ភ្ញាក់ក្រញាង មកឱបកូន មកបបោសអង្អែលកូនយកចិត្តកូន ... ។

មាតាបិតាប្រុងភ្នែក ប្រុងត្រចៀក ប្រុងសព្វគ្រប់ប្រុងទាំងយប់ ប្រុងទាំងថ្ងៃ ដើម្បីរក្សាកូនស្ងួនសម្លាញ់ដែលជាសាច់ឈាមរបស់ខ្លួន ទោះជាទេវតាដោយកំណើតមានកិច្ចរក្សានូវលោកនេះ ក៏គង់មានពេលភ្លេចក្នុងកិច្ច



រក្សាដែរ ប៉ុន្តែមាតាបិតាមិនធ្លាប់ភ្លេចកូននិងមិនបានបោះបង់កូនឡើយ គឺលោកទាំងពីរតែងគ្រប់គ្រងរក្សាឱ្យកូនបានសុខរហូតមក ។

## ព្រះគុណរបស់ម៉ែ ជា ជម្រកមនោរម្យទ្រនំកូន

**ព្រះ** ម៉ែយកខ្នងបាំងកម្តៅថ្ងៃ យកទ្រូងថ្នើមថ្លៃ ធ្វើទី **ជម្រក**
**គុណ** ម៉ែជាម្លប់ឱ្យកូនបានជ្រក ខ្នងម៉ែពងពកកូនសុខ **មនោរម្យ** ។
**របស់** សំខាន់គឺខ្លួនប្រាណម៉ែ តែ ម៉ែ បង្វែរ យក ជា **ទ្រនំ**
**ម៉ែ** ខ្លាចព្យុះភ្លៀងចាញ់ខ្លាចកូនយំ កូនរស់បានធំម៉ែលាចាក **កូន** ។

## ព្រះគុណរបស់ឪជា ឋានព្រហ្មជីវិតកូន

**ព្រះ** បង្កើតកូនមានឈ្មោះថាឪ មិនមែនព្រះនៅក្នុងសួគ៌ា **ឋាន**
**គុណ** ឪមាននៅក្នុងចិត្តសន្តាន កូនបានសុខសាន្តព្រោះឪជា **ព្រហ្ម** ។
**របស់** ពិសេស គឺកូន ឪ ពិត ឪ ប្តូរ ជីវិត ប្រឹង សាង **ជីវិ**
**ឪ**ធ្វើការខ្លាំងនឿយហត់ប៉ុនភ្នំ តែសុខមនោរម្យព្រោះឃើញមុខ**កូន** ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ម៉ែឪនឹកកូន-កូនទៅនៅរៀនថ្នាំម៉ា

**ម៉ែ** សម្រាលកូនឪអរខ្លាំង ចិត្ត តាំង សច្ចា ចិញ្ចឹម **កូន**
**ឪ** នឿយយ៉ាងណាបិទមាត់ស្ងួន្យ ពេលនឹកដល់កូន ចិត្តត្រាច់**នៅ** ។
**នឹក** ដល់កូនខ្លាំងឪខំប្រឹង សម្លឹង កិច្ចការ ចិត្តជាប់ **នៅ**
**កូន** អើយថ្ងៃនេះឪទុក្ខជ្រៅ ព្រោះឮកូនទៅ **រៀនថ្នាំម៉ា** ។
ដំណឹងនេះកាច ក្រៃអាក្រក់ ដូច មច្ចុ ឆក់ ផ្តាច់ សង្ខារ
កូនមាសឪពុក សូមមេត្តា ករុណា ម៉ែឪ ត្រង់ នេះ ផង ។



## កូនមាសឪពុក

មាតាបិតាគឺជាព្រះព្រហ្មប្រចាំផ្ទះរបស់កូន មាតាបិតាគឺជាព្រហ្មមុខ៤ ពិត។ ព្រោះមាតាបិតាមានព្រហ្មវិហារ៤យ៉ាង គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ។

មាតាបិតាប្រាថ្នាឱ្យកូនមានសេចក្តីសុខ ទើបហាមកូនមិនឱ្យធ្វើអំពើបាបដែលជាអំពើខុសទាំងច្បាប់ ខុសទាំងសីលធម៌ ព្រោះថាបើកូនប្រព្រឹត្តធ្វើនូវអំពើបាបអាក្រក់ផ្សេងៗហើយ កូនរមែងទៅជាមនុស្សថោកទាប ទៅជាអ្នកទោស ទៅជាមនុស្សដែលសង្គមស្អប់ខ្ពើម មាតាបិតាមិនប្រាថ្នាឱ្យកូនរបស់ខ្លួនក្លាយទៅជាបែបហ្នឹងឡើយ មាតាបិតាខ្លោចផ្សាក្នុងចិត្តណាស់ កាលបើកូនរបស់ខ្លួនត្រូវគេចាប់យកទៅធ្វើទារុណកម្ម ព្រោះហេតុដូច្នោះ ទើបមាតាបិតាខំប្រឹងទូន្មានកូនមិនឱ្យធ្វើនូវអំពើអាក្រក់ផ្សេងៗដែលជាអំពើបាប ។

មាតាបិតាប្រាថ្នាឱ្យកូនមានសេចក្តីសុខ ទើបដាស់-

តឿនកូនឱ្យប្រព្រឹត្តនូវអំពើល្អ កាលណាកូនប្រព្រឹត្តល្អ ហើយ អ្នកផងទាំងពួងក៏ចូលចិត្ត ស្រឡាញ់រាប់អាន ពោលសរសើរ មាតាបិតាសប្បាយចិត្តណាស់ កាលបើមានអ្នកដទៃសរសើរកូនរបស់ខ្លួន ម្យ៉ាងទៀត មាតាបិតារមែងហួងហែងអនាគតរបស់កូន ប្រាថ្នាឱ្យកូនបានទៅកាន់សុគតិភព ដោយការប្រព្រឹត្តនូវសុចរិតកម្មរបស់កូនខ្លួនឯងផ្ទាល់ ព្រោះហេតុដូច្នេះ ទើបមាតាបិតាខំប្រឹងអប់រំទូន្មាននិងដឹកនាំកូនឱ្យធ្វើនូវបុណ្យបំពេញកុសលផ្សេងៗ។

មាតាបិតាប្រាថ្នាឱ្យកូនមានសេចក្តីសុខ ដោយបានដឹងខ្លួនច្បាស់ថា ខ្លួនជាមាតាបិតាមិនអាចនៅគ្រប់គ្រងកូនប្រុសស្រីបានរហូតឡើយ ព្រោះហេតុដូច្នេះហើយ ត្រូវឱ្យកូនសិក្សារៀនសូត្រ ស្វែងរកចំណេះដឹងមកដាក់ខ្លួន ឱ្យកូនមានវិជ្ជាក្នុងខ្លួន មានខ្លួនឯងជាទីពឹងតទៅ ជាធម្មតាមាតាបិតាដែលមានកូនល្ងង់ វាលំបាកក្រៃលែងជាងមានរោគក្នុងខ្លួនឯងទៅទៀត ដូច្នេះ ជាចាំបាច់បំផុត មាតាបិតាត្រូវតែឱ្យកូនចូលសាលា បានសិក្សារៀនសូត្រ ។



មនុស្សយើងមិនអាចកសាងខ្លួនបានឡើយ បើជាមនុស្សល្ងង់មិនមាននូវចំណេះវិជ្ជាទេនោះ ។

មនុស្សល្អហើយចេះតែល្អតៗទៅ ដោយអាស្រ័យហេតុពីរយ៉ាង :

១-ស្វែងរកវិជ្ជាមកដាក់ខ្លួន ព្រមទាំងបានចេះដឹងអំពីហេតុនៃសេចក្តីវិនាស និងហេតុនៃសេចក្តីចម្រើនទៀតផង ។

២-បដិបត្តិជាប្រចាំ ពោលគឺការប្រព្រឹត្តតាមការដែលខ្លួនបានចេះដឹងនោះ ដោយសេចក្តីមិនប្រមាទ ។

កូនមាសឪពុក មិនត្រូវខឹងក្រោធនឹងពាក្យដាស់តឿនក្រើនរំលឹករបស់មាតាបិតាឡើយ កូនត្រូវយល់ថាមាតាបិតាមិនអាចចេះតែស្រឡាញ់កូន ហើយបណ្តោយកូនឱ្យដើរក្នុងផ្លូវនៃសេចក្តីវិនាសនោះឡើយ ។

សេចក្តីស្រឡាញ់កូនវាជាអាវុធមុខពីរ បើស្រឡាញ់ដោយខ្វះបញ្ញា ពោលគឺ ខ្វះការគ្រប់គ្រងកូនឱ្យបានដិតដល់ និងការដែលចេះតែបណ្តែតបណ្តោយតាមចំណង់





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

របស់កូន សេចក្ដីស្រឡាញ់បែបនេះ វាជាការប្រហារនូវសេចក្ដីសុខរបស់កូនផង ប្រហារនូវសេចក្ដីសុខរបស់ខ្លួនឯងផង ព្រោះហេតុដូច្នេះហើយ ទើបព្រហ្មវិហារធម៌របស់មាតាបិតាដែលមានទៅលើបុត្រធីតា គឺត្រូវឱ្យគ្រប់ ៤ ។

មាតាបិតា មិនត្រូវមានត្រឹមតែមេត្តា ករុណា និងមុទិតានោះទេ ត្រូវចេះមានឧបេក្ខាផង ឧបេក្ខាដែលមានដោយត្រឹមត្រូវទៅបាននោះ លុះត្រាតែមាតាបិតាមានបញ្ញាយល់ត្រូវនូវច្បាប់របស់ធម្មជាតិ ។

ជីវិតសត្វលោកទាំងអស់គឺជាធម្មៈ បានដល់ធម៌ដែលប្រព្រឹត្តទៅតាមហេតុ ដូច្នេះកូនប្រុសស្រីមិនអាចសម្រេចបាននូវអ្វីៗ គ្រប់យ៉ាងទៅតាមការប្រាថ្នារបស់ខ្លួនឯងឡើយ មាតាបិតាក៏មិនអាចឱ្យសម្រេចបានគ្រប់យ៉ាងដែរ សរុបសេចក្ដីមកគឺថា កូនប្រុសស្រីមិនមែនរស់នៅតែជាមួយមាតាបិតានោះទេ គឺរស់នៅជាមួយច្បាប់ផង ទាំងច្បាប់របស់សង្គម ទាំងច្បាប់របស់ធម្មជាតិ ត្រង់ចំណុចនេះឯងហើយ ដែលថា មាតាបិតាមិនអាចមានតែមេត្តា



ករុណា និងមុទិតាបាននោះ ព្រោះកូនប្រុសស្រីមិនមែនរស់នៅតែជាមួយខ្លួនដែលជាមាតាបិតាឡើយ ។

ឧបេក្ខារបស់មាតាបិតា ដែលជាឧបេក្ខាព្រហ្មវិហារ មិនមែនបានសេចក្ដីថា មិនរវល់ មិនខ្វល់ ធ្វើព្រងើយៗ ដោយឥតយកចិត្តទុកដាក់នោះឡើយ ការព្រងើយរបៀបនេះគឺជាឧបេក្ខាក្នុងសេចក្ដីល្ងង់ទៅវិញទេ ។

ឧបេក្ខាព្រហ្មវិហារជាគុណដ៏ក្រៃលែង ជាធម្មតាមុខព្រហ្មទាំង៤ មិនមែនល្អតែ៣ ឯមុខមួយទៀតអាក្រក់នោះឡើយ ។

ឧបេក្ខាព្រហ្មវិហារមិនមែនជាឧបេក្ខាវេទនាទេ អង្គធម៌គឺ <u>តត្រមជ្ឈត្តតាចេតសិក</u> ជាសោភណធម៌មួយដែលល្អជានិច្ច មាតាបិតាដែលមានឧបេក្ខាព្រហ្មវិហាររមែងតែងតែសម្លឹងមើលជីវិតរបស់កូន ដោយការចេះដឹងក្នុងហេតុផលនៃជីវិត ហើយតែងតែអប់រំកូនឱ្យចេះរស់នៅជាមួយនឹងច្បាប់ បង្ហាត់បង្រៀនកូនឱ្យចេះមានខ្លួនជាទីពឹង ប្រាប់កូនពីហេតុនៃសេចក្ដីវិនាសនិងហេតុនៃសេចក្ដីចម្រើន ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ព្រហ្មវិហារធម៌៤ ត្រូវចែកជាពីរចំណែកគឺ មេត្តា ករុណា និងមុទិតាជាចំណែក១ ឯឧបេក្ខាជាចំណែក១ ចំណែក១ខាងដើមគឺ បានចិញ្ចឹមកូនឱ្យរស់ ឱ្យការកក់ក្តៅដល់កូនគ្រប់គ្រាគ្រប់ពេលវេលា ឯចំណែក១ទៀតគឺ ឧបេក្ខា ជាការសម្លឹងមើលដំណើរជីវិតរបស់កូន ហើយញ៉ាំងឱ្យកូនចេះរស់នៅដោយខ្លួនឯង ធម៌ទាំង២ចំណែកនេះ មិនអាចបែកគ្នា ឬថាមានតែមួយចំណែកបានឡើយ ព្រោះថាបើមានតែឧបេក្ខាព្រហ្មវិហារ កូនរមែងកម្សត់រងាតែលតោល ប៉ុន្តែបើមានតែមេត្តា ករុណា និងមុទិតា កូនប្រាកដជាមិនចេះក្រោកឈរដោយខ្លួនឯងឡើយ ពោលគឺត្រូវខ្វះសមត្ថភាពដើម្បីជាទីពឹងឱ្យដល់ខ្លួនឯង ក្លាយទៅជាមនុស្សពិការទាំងដែលមានអវយវៈគ្រប់គ្រាន់ ឬក្លាយទៅជាជនទុច្ចរិត ។

មាតាបិតាជាព្រះព្រហ្មរបស់កូន ដោយព្រហ្មវិហារធម៌៤យ៉ាងគឺ មានទាំងចំណែកស្រឡាញ់ដោយមេត្តា មានទាំងចំណែកទីពឹងឱ្យកូនប្រាសចាកទុក្ខ ដោយករុណា មាន



ទាំងចំណែកចិត្តទន់ភ្លន់ ទោរទន់ជាមួយកូនដោយមុទិតា និងមាននូវចំណែកបណ្តុះបណ្តាល បង្វឹកបង្ហាត់ឱ្យកូនចេះរស់នៅក្នុងលោកបានដោយខ្លួនឯងគឺ ឧបេក្ខាព្រហ្មវិហារជាគម្រប់៤ ។

## ព្រហ្មវិហារ៤យ៉ាង

**មេត្តា**ប្រែថាការរាប់អាន ដូចមិត្តកល្យាណបានសង្គ្រោះ
ជួយផ្តល់ប្រយោជន៍ឱ្យបានរស់ សង្គ្រោះឱ្យសុខគ្រប់ៗគ្នា ។
**ករុណា**ប្រែថាការអាណិត មានចិត្តចង់ជួយជនកំព្រា
ឱ្យមានទីពឹងបានសុខជា មនុស្សសត្វគ្រប់គ្នាផុតទុក្ខា។
**មុទិតា**ប្រែថាការទន់តាម ចិត្តឥតជិតដាមដោយឥស្សា
ត្រេកអរទន់ភ្លន់ស្រស់ភក្ត្រា ចិន្តាបរិសុទ្ធផុតព្យាបាទ។
**ឧបេក្ខា**ប្រែថាការសម្លឹង មិនធូរមិនតឹងប្រឹងសង្វាត
ឱ្យត្រង់តាមច្បាប់តាមក្បួនខ្នាត ចិត្តស្អាតត្រឹមត្រូវតាម
ហេតុផល ។

# មាតាបិតាសង្គ្រោះកូន
# ដោយធម៌៥យ៉ាង

**មាតាបិតា** ជាគ្រូដើម ជាគ្រូដ៏ផ្ដើមក្នុងលោកា
ម្យ៉ាងទៀតគឺពិតជាទេវតា ព្រះពុទ្ធត្រាស់ថាជាព្រហ្មផង។
មាតាបិតាគឺជាព្រះ រស់នៅក្នុងផ្ទះដ៏ច្បាស់ច្បង
សង្គ្រោះ៥យ៉ាងល្អហ្មត់ហ្មង ចម្លងបុត្រភ្ញាឱ្យដល់ត្រើយ។
**សង្គ្រោះទី១** ដោយការឃាត់ មិនឱ្យកូនភ្លាត់ធ្វើបាបឡើយ
ឃើញកូនធ្វើខុសឥតកន្តើយ ហាមហើយហាមទៀតផ្ទៀតតាមឃ្លាំ។
កំណើតជាមនុស្សថ្លៃពេកពន់ កូនត្រូវអត់ធន់ឱ្យបានសម
កុំឱ្យចំណង់វាបង្ខំ ចូលជ្រាំធ្លាក់ជ្រោះរស់អសោច។
**សង្គ្រោះទី២** ដោយការនាំ ផ្សំផ្សំសន្សំគុណប្រយោជន៍
នៅរស់ជាមនុស្សកុំជាខ្មោច យ៉ាងហោចត្រូវឱ្យមានសីល៥។
ម៉ែឪបំពាក់អលង្ការ គឺធម៌ទេសនាជាប្រចាំ
កូនត្រូវស្រឡាញ់កល្យាណកម្ម គុណគាប់ត្រូវចាំកុំបំភ្លេច ។



**សង្គ្រោះទី៣** គឺឱ្យរៀន អុចទៀនវិជ្ជាភ្លឺរំលេច
សម្បត្តិចំណេះថ្លៃជាងពេជ្រ ដាច់ខាតត្រូវគេចពីគ្រឿងញៀន។
ថ្នាំញៀនបំផ្លាញនូវស្មារតី ញៀនល្បែងអប្រីយ៍នាំខូចរៀន
ញៀនស្រាញៀនស្រីរោគបៀតបៀន បើញៀននឹងរៀនសុរិយារះ ។
**សង្គ្រោះទី៤** គឺរៀបការ ក្នុងរឿងប្រាថ្នាគ្រប់គ្រងផ្ទះ
មិនត្រូវបង្ខំចង់យកឈ្នះ មានះនាំខូចប្រយោជន៍ធំ។
ស្នេហាជាផ្នូរកប់ព្រលឹង រឿងហ្នឹងត្រូវដឹងឱ្យគ្រប់មុំ
កុំអាងថានាឡិធំជាងនំ មានរឿងទាវទុំគំរូស្រាប់ ។
**សង្គ្រោះទី៥** គឺចែកទ្រព្យ តាមកាលគួរគាប់ជាប់ជាច្បាប់
មរតកជាទ្រព្យនៃអ្នកស្លាប់ មិនត្រូវប្រញាប់ឱ្យដាច់ឡើយ។
ឱ្យតិចឱ្យច្រើនជាប្រចាំ រាល់ថ្ងៃខែឆ្នាំឱ្យណាស់ហើយ
ចំណែកសម្បត្តិនាំដល់ត្រើយ ដូចបានពោលហើយគឺឱវាទ។
សង្គ្រោះ៥យ៉ាងគឺជាគុណ ជាទុនជីវិតតាមក្បួនខ្នាត
ម៉ែឪជាព្រះអ្នកនាំអាទិ៍ កូនកុំប្រមាទតទៅហោង។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ព្រហ្មលិខិត

ជំនឿសាសនាព្រហ្មលិខិត　　រៀបចំវិចិត្រសព្វលោកីយ៍
មនុស្សទេវតាភ្លើងទឹកដី　　គ្មានអ្វីថាព្រហ្មមិនតាក់តែង។
បើព្រហ្មតាក់តែងលោកយ៉ាងនេះ យើងគួរត្រិះរិះតាមជាក់ស្តែង
រកហេតុរកផលសព្វកន្លែង　　ប្រឹងប្រែងស្វែងរកនូវការពិត។
ហេតុអ្វីមនុស្សយើងមិនដូចគ្នា　　មានជា មានឈឺ ភ្លឹងធឹត
មានក្រសខ្មៅខ្លៅបណ្ឌិត　　ទាំងការប្រព្រឹត្តខុសគ្នាឆ្ងាយ។
ចំណែកតិរច្ឆានបានមិនល្អ　　មាននឹមទាក់កគួរឱ្យណាយ
សត្វច្រើនទុក្ខខ្លាំងក្នុងអបាយ　　ប្រេតអសុរកាយនិងអវិចី ។
ក្រៅពីមនុស្សសត្វក៏ឃើញច្បាស់　　ខ្យល់ព្យុះខ្លាំងណាស់កក្រើកដី
ភ្នំភ្លើងទឹកជន់ឥតប្រណី　　រាំងភ្លៀងងាប់ត្រីស្អីតាក់តែង។
ព្រះពុទ្ធត្រាស់ដឹងពីធម្មជាតិ　　រូបធាតុនាមធាតុទ្រង់សម្តែង
សត្វលោកនៅលើកម្មចាត់ចែង ឥឡូវសូមថ្លែងពីម៉ែឪ ។
នៅពេលមានគភ៌ពីរបីខែ　　បើម៉ែលិខិតមិនឱ្យនៅ
កូនឋិតក្នុងផ្ទៃមុខតែត្រូវ　　អស់ផ្លូវបានកើតឃើញសូរ្យសែង។



កូនខ្លះឪមិនទទួលស្គាល់　　លិខិតដោយផ្ទាល់ថាអ្នកឯង
មិនមែនកូនអញយ៉ាងជាក់ស្តែង កូនត្រូវចំបែងមួយជីវិត ។
កូនខ្លះកើតមកម៉ែបោះចោល ស្លាប់រស់តែលតោលម៉ែមិនគិត
កូនខ្លះត្រូវឪចាប់ជំរិត　　រំលោភប្រព្រឹត្តអនាចារ ។
កូនខ្លះកើតចំឪប្រមឹក　　វាយម៉ែពេលផឹកស្រវឹងស្រា
ទាំងកូនក្នុងផ្ទៃដួលផ្កាប់ផ្ងារ　　កូនណារស់ធំដើរសុំទាន ។
កូនខ្លះម៉ែឪលែងលះគ្នា　　គ្រាំគ្រាគ្រួសារដូចបាក់ស្ពាន
កូនខ្លះរស់ខ្វះការទូន្មាន　　ប្រៀបដូចជិះយានភ្លូកធ្លាក់ជ្រោះ។
ព្រហ្មមានមុខ៤ពិតប្រាកដ　　តែបើព្រហ្មខ្សត់ពិតជាគ្រោះ
ព្រោះព្រហ្មអត់មុខឱ្យកូនរស់　　ខ្វះធម៌សង្គ្រោះ៥ប្រការ ។
ម៉ែឪជាព្រហ្មលិខិតកូន　　ចាត់ចែងឱ្យសូន្យឬភ្លឺថ្លា
បើពិតជាព្រហ្មត្រូវមេត្តា　　មុខថ្លាស្រស់ដូចព្រហ្មបាយ័ន។
ម៉ែឪមានព្រហ្មវិហារធម៌　　ចាប់ផ្តើមតាំងគភ៌មិនធុញទ្រាន់
ព្រោះមេត្តាចិត្តកើតរួសរាន់　　ក្នុងចិត្តបន្ទាន់ឱ្យគ្រប់ខែ ។
ចង់ឃើញមុខកូនស្ងួនពិសី　　ទោះប្រុសឬស្រីក៏កូនដែរ
ខំរក្សាគភ៌ពិតជាម៉ែ　　ឪខំធ្វើស្រែប្រមូលទ្រព្យ ។

ពេលឆ្លងទន្លេម៉ែឈឺណាស់ ឈឺក្រៃឈឺក្រាស់ហួសរៀបរាប់
ដោយម៉ែស្រឡាញ់កូនសំណព្វ ជាភ័ព្វជួយឱ្យសតិតាំង ។
បានឃើញមុខកូនម៉ែសប្បាយ ទឹកមុខស្រស់ស្រាយទាំងស្លេកស្លាំង
ព្រោះអម្បាញ់មិញម៉ែឈឺខ្លាំង រួចហើយម៉ែតាំងបំបៅដោះ។
ម៉ែស្រឡាញ់កូនម៉ែថ្នាក់ថ្នម បំពេបីបមមិនឱ្យខ្វះ
ម៉ែជាព្រះព្រហ្មព្រោះចិត្តស្មោះ ក្នុងលោកល្អស្រស់ព្រោះគុណម៉ែ។
ម៉ែឪជាព្រហ្មលិខិតលោក ប្រោះព្រំជ័យជោគលោកបានល្វែ
កុំភ្លេចឱ្យសោះព្រះគុណម៉ែ ឪពុកផងដែរអ្នកសាងលោក។
ខ្លួនប្រាណជើងដៃមនុស្សទាំងអស់ រួមទាំងរបស់គ្រឿងបរិភោគ
អាស្រ័យព្រះគុណអ្នកសាងលោក កូនស្វាងចាកងោកទើបយល់ត្រូវ។

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## កូនត្រូវចេះគិត

អ្វីៗក្នុងលោកកើតព្រោះហេតុ ឃើញច្បាស់ក្រឡែតគុណម៉ែឪ
កូនរស់ធំឡើងត្រូវរកផ្លូវ សងគុណម៉ែឪទើបត្រូវច្បាប់។
បើមិនបានសងអ្វីធំដុំ កុំតែស្រីម៉ុមប្រែក្រឡាប់
រត់ចេញពីផ្ទះមិនបានប្រាប់ ប្រញាប់តាមប្រុសព្រោះស្នេហា។



ចំណែកកូនប្រុសក៏ដូចគ្នា កុំធ្វើឫកពាមនុស្សបាតផ្សារ
ប្រគល់ខ្លួនប្រាណឱ្យស្រីស្រា រោគផ្កាច់សង្ខារចោលម៉ែឪ។
ម៉ែឪចិញ្ចឹមដប់ម្ភៃឆ្នាំ កូនបានធ្វើកម្មកើរ្តិ៍អាស្រូវ
ចុះចេញពីផ្ទះបាត់ភ្លាមទៅ តើឱ្យម៉ែឪនៅសល់អ្វី ។

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## អាសូរចិត្តម្តាយ

ពេលកូនកើតមកម៉ែសប្បាយ ទោះអត់ប្រាក់ចាយមិនចេញស្តី
ស៊ីឈ្នួលធ្វើការប្រឹងរែកដី លំបាកម្តេចក្តីឥតមានថ្ងូរ ។
ទទូរក្រមានៅហាលថ្ងៃ យកដៃជូតញើសដែលវាហូរ
ពេលនឹកដល់កូនចិត្តទន់ទោរ ញើសហូរមិនស្មើចិត្តស្រឡាញ់។
មានគេសួរថាខំអ្វីម្ល៉េះ ថ្ងៃក្តៅសឹងឆេះមិនចេះចាញ់
ម៉ែឆ្លើយថាព្រោះកូនសម្លាញ់ គិតកាញ់រកប្រាក់កុំចង់ល្វែ ។
ធ្វើម្តេចកូនខ្ញុំកំព្រាឪ តាំងតែពីនៅក្នុងពោះម៉ែ
ខ្ញុំប្រឹងចិញ្ចឹមបីបាច់ថែ រហូតទាល់តែឥឡូវនេះ ។
ពេលនេះកូនខ្ញុំពេញកំលោះ រូបរាងស្រស់បស់មិនសំគិស





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ខ្ញុំបានទិញកង់ឱ្យកូនជិះ ខ្ញុំរិះកំណាញ់តែមាត់ឯង ។
ខ្ញុំឱ្យកូនរៀនដល់ថ្នាក់ខ្ពស់ ដើម្បីកូនរស់ខ្ញុំប្រឹងប្រែង
ធ្វើការរាល់ថ្ងៃខ្ញុំរអែង ខ្លាចក្រែងតែកូនប្រឡងធ្លាក់។
ម៉ែឆ្លើយរៀបរាប់ពីកូនគាត់ ចិត្តម៉ែមិនព្រាត់ពីកូនជាក់
ចិត្តម៉ែដូចទឹកហូរទម្លាក់ ហូរឥតមានទាក់រកកូនប្រុស។
កូនប្រឡងធ្លាក់ម៉ែស្លុតចិត្ត អាណិតថាកូនឥតកំហុស
កូនគាត់ពូកែឥតមានខុស តែព្រោះកូនប្រុសអត់ប្រាក់សូក។
តាមពិតកូនគាត់វាខ្ជិលរៀន រវល់តែញៀនគ្រឿងស្មោកគ្រោក
ម៉ែខំធ្វើការបែកញើសជោក កូនគាត់កើតរោគមិនដឹងខ្លួន។
កូនរឹតតែស្គមម៉ែខ្លោចចិត្ត អាណិតថាកូនខំរៀនផ្ទួន
កូនចេញបាត់ៗដោយបិទពួន កុហកម៉ែខ្លួនថារៀនឈ្នួល។
ម៉ែខំរកប្រាក់ឱ្យកូនរៀន ប្រិតប្រៀនដាំបាយរៀបសម្រួល
ក្រៃលែងជាងខ្ញុំដែលគេជួល ឃើញកូនមិនស្រួលនាំទៅពេទ្យ។
គ្រាកាលព្រាត់ប្ដីម៉ែមិនស្លុត គ្រាន់តែស្រយុតចិត្តស្រឡេត
លើកនេះដឹងថាកូនកើតអេដស៍ ម៉ែស្លុតចូលពេទ្យឈប់ពោលស្ដី។



## ឪពុកម្ដាយជាព្រះអរហន្តរបស់កូន

ទឹកចិត្តរបស់ព្រះអរហន្ត ដែលមានចំពោះពពួកជនហ្មត់ចត់យ៉ាងណា ទឹកចិត្តរបស់ឪពុកម្ដាយដែលមានចំពោះកូន ក៏ហ្មត់ចត់ដូច្នោះដែរ ។

សូមកូនទាំងឡាយ កុំវាយតម្លៃទឹកចិត្តរបស់មាតាបិតា ដែលជាព្រះអរហន្តក្នុងផ្ទះ ឱ្យស្មើនឹងទ្រព្យសម្បត្តិណាៗក្នុងលោកឱ្យសោះ ព្រោះវៀរលែងតែព្រះអរហន្តដែលអស់កិលេសហើយ ក្នុងលោកនេះមិនមាននរណាប្រាថ្នាល្អចំពោះកូនយ៉ាងពិតប្រាកដ ឱ្យដូចជាឪពុកម្ដាយរបស់កូនឡើយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពេលនឹកដល់ព្រះ ត្រូវនឹកដល់ផ្ទះ

បើកូនកំពុងស្វែងរកព្រះអរហន្ត ដើម្បីក្រាបថ្វាយ-បង្គំ សូមឱ្យនឹកដល់ផ្ទះរបស់កូន ។

មាតាបិតា គឺជាព្រះអរហន្តក្នុងផ្ទះរបស់កូន ព្រោះទឹកចិត្តរបស់មាតាបិតាមានសភាពបរិសុទ្ធដល់កូនប្រុសស្រីប្រៀបបីដូចជាទឹកចិត្តរបស់ព្រះអរហន្ត ដែលអស់កិលេសដូច្នោះឯង ។



# កូនត្រូវតែយល់ដឹង

តើមានមនុស្សប៉ុន្មាននាក់ដែលបានដឹងថា មាតាបិតា គឺជាព្រះក្នុងផ្ទះ គេច្រើនតែស្វែងរកនិងបូជាចំពោះព្រះដែលនៅក្រៅផ្ទះតែប៉ុណ្ណោះ ចំណែកព្រះក្នុងផ្ទះដែលមានខ្យល់ដកដង្ហើមចេញចូលនៅឡើយ ហើយថែមទាំងនៅជិតបង្កើយជាមួយនឹងគេគ្រប់ពេលវេលានោះ គេបែរជាមើលរំលងហួសផុតទៅវិញ គួរឱ្យសង្វេគ ។

ដូច្នេះកូនត្រូវតែយល់ដឹង ហើយបដិបត្តិយកនូវមង្គលមកឱ្យជីវិតរបស់កូន កុំឱ្យហួសពេលឡើយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ស្រឡាញ់កូនគ្រប់វេលា

សូម្បីតែកូនចម្រើនធំធាត់ពេញវ័យ មានទូវភរិយាស្វាមីទៅហើយក៏ដោយ ក៏នៅក្នុងក្រសែភ្នែករបស់ឪពុកម្ដាយគឺកូននៅជាក្មេងជានិច្ច ...

គឺជាក្មេងក្នុងសេចក្ដីដឹងខ្លួនរបស់ឪពុកម្ដាយ ដែលឪពុកម្ដាយមានតែការស្រឡាញ់និងអាណិតអាសូរប៉ុណ្ណោះ ជាក្មេងដែលឪពុកម្ដាយចង់តែទូន្មានប្រៀនប្រដៅជាដរាប ជាក្មេងដែលឪពុកម្ដាយត្រូវដាស់តឿននៅពេលធ្វើខុសនិង ជាក្មេងដែលឪពុកម្ដាយហួងហែងរហូត ។

✍📖✍



## អ្នកឱ្យជីវិតដល់កូន

ឪពុកម្ដាយ គឺជាអ្នកប្រគល់ជីវិតឱ្យដល់កូនធ្វើឱ្យកូនបានបើកភ្នែកឃើញនូវលោកនេះ រួចហើយឪពុកម្ដាយបានការពារភយន្តរាយ មិនឱ្យមានមកដល់កូនឡើយ... រហូតដល់កូនបានធំពេញវ័យ ឪពុកម្ដាយព្យាយាមសាងនូវអនាគតដ៏ល្អឱ្យដល់កូនសព្វគ្រប់ប្រការ មាតាបិតាពិតជាព្រះនៅក្នុងផ្ទះប្រាកដមែន ។

✍📖✍

## មិនអាចបដិសេធបាន

ជីវិតកូនដែលជាប់ដោយខ្យល់ដង្ហើមចេញចូលនេះ កូនមិនអាចបដិសេធបានថា មិនមែនជារបស់ឪពុកម្ដាយនោះឡើយ ព្រោះកូនមិនអាចបាននូវជីវិតនេះមកទេ បើប្រាសចាកម៉ែឪទៅហើយនោះ ដូច្នេះទើបមាតាបិតាសមគួរនឹងបានទទួលនូវគ្រឿងសក្ការបូជាអំពីកូនដោយពិត ។



## យកចិត្តទុកដាក់ជាមួយព្រះក្នុងផ្ទះ

មនុស្សយើងមានព្រះនៅក្នុងផ្ទះគ្រប់គ្នា អ្នកខ្លះមានឪពុកអត់ម្ដាយ អ្នកខ្លះនៅសល់ម្ដាយអត់ឪពុក អ្នកខ្លះទៀតមានជោគល្អ គឺនៅមានទាំងឪពុក នៅមានទាំងម្ដាយ ។

កូនត្រូវយកចិត្តទុកដាក់ មើលថែទាំអ្នកមានគុណឱ្យបានល្អ បើមិនដូច្នោះទេ វានឹងហួសពេល ព្រោះទម្រាំតែនឹករលឹកឃើញថា ត្រូវយកចិត្តទុកដាក់ថែទាំនោះ លោកទាំងពីរអាចបាត់ខ្លួនពីក្នុងលោកនេះរហូតទៅហើយ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## សំណូមពរចុងក្រោយ

**កូនមាសឪពុក** សូមកូនជួយឱ្យឪពុកម្តាយបានសម្រេចបំណង ដែលជាទិសដៅនៃការអប់រំចិញ្ចឹមកូន គឺសូមឱ្យកូនបានជាមរតកដ៏សំខាន់បំផុត ជាមរតកដែលឪពុកនិងម្តាយរបស់កូន ប្រគល់ឱ្យដល់ប្រទេសជាតិ និងពិភពលោក ។

កាលបើឪពុកម្តាយបំពេញតួនាទី របស់ម៉ែឪបានសម្រេច ដោយកូនមាសឪពុកជាមនុស្សល្អហើយ ឪពុកនិងម្តាយរបស់កូនក៏មាននូវសេចក្តីសុខ ព្រោះសមតាមបំណងដែលបានគិតទុកតាំងពីកូននៅក្នុងផ្ទៃម្ទេះ និងម្យ៉ាងទៀតម៉ែឪសប្បាយចិត្ត ត្រង់ដែលមានអ្នកបន្តវង្សត្រកូលដ៏ល្អ គឺមាននូវចំណេះដឹងនិងមានការប្រព្រឹត្តយ៉ាងរៀបរយ ។

ឪពុកសូមយកចិត្តដ៏បរិសុទ្ធស្មោះ មកឱ្យពរដល់កូនសូមឱ្យតទៅ កូនទាំងឡាយបាននូវទាយាទដ៏ល្អ ប្រព្រឹត្តតាមស្នាមដ៏ប្រពៃជាបន្តទៅទៀត នេះជាសច្ចវាចា ។

**ពីឪពុករបស់កូន**



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១-ឧបាសក សំរ៉ង វណ្ណ | ២-ឧបាសក យន្ត សួន |
| ៣-ឧបាសក គួង លាងផេង | ៤-ឧបាសក មួង យេន |
| ៥-ឧបាសក រស់ សូផាត | ៦-ឧបាសក គុយ សុធន |
| ៧- នាង ជា សុណារី | ៨- នាង ឃុន សូនីម៉ា |
| ៩-ឧបាសិកា ហួន ចាន់បូដា | ១០-ឧបាសក វ៉ាន់ ខុនណា |

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយធម៌ប្រចាំឆ្នាំ

១- ឧបាសក យូស៊ាង-ងួនលី និង ឧបាសិកា លីម-ឃីម

២- ឧបាសក ឆាយ-អ៊ីវស៊ាង និងឧបាសិកា ហុង-គឹមសែ

៣- ឧបាសកឆាយអ៊ីវ-ស្រេងលីម និងឧបាសិកាហួត-ឃីម

៤- ឧបាសកហៃ-ប៊ុនណារិន និងឧបាសិកាអោង-ស៊ីថាន់

៥- ក្រុមឧបាសក ឈុំ-កុសល និងឧបាសក អ៊ុន-ឆាយគ្រី

៦- ក្រុមឧបាសក លឹម -ស៊ាង ( ហៅ ទូច )

៧. ឧបាសក  យន្ត. សួន  និងភរិយា  ព្រមទាំងបុត្រ

៨. ឧបាសក ប៊ុន.ហេង ឧបាសិកា ជុំ.សុខុម ព្រមទាំងបុត្រ

៩. ឧបាសិកា ឱម.លក្ខណា  ព្រមទាំងបុត្រ

១០. ឧបាសិកា ញឹក.ប៊ុនថា និងឧបាសិកា ម៉ែន.សុភារី

១១. ឧបាសិកា  ច័ន្ទ.បុប្ផាណា  ព្រមទាំងបុត្រ

១២. ឧបាសិកា ស្រង់.ឡេង ព្រមទាំងបុត្រ

១៣. ឧបាសក  អ៊ុត .ឆៃវ៉ាន  និងភរិយា ព្រមទាំងបុត្រ

១៤. ឧបាសក ប្លោក .ងួនថៃ និងភរិយា  ព្រមទាំងបុត្រ

១៥. ឧបាសក ជឹម .អេងស្រ៊ន និងភរិយា  ព្រមទាំងបុត្រ

១៦. ក្រុមឧបាសក  មួង  .យេន (វត្តសំពៅមាស)

១៧. ឧបាសិកា  ជី.ឡាង

១៨. លោកម៉ៅ.សុគន្ធ អ្នកស្រី យ៉េក.ហួយ ព្រមទាំងបុត្រ

១៩. លោកយាយ ម៉េង.ហ៊ន

២០. ឧបាសក សំរ៉ង.វ័ណ្ណ  និងឧបាសិកា  សេង.គីមលន់

២១. ឧបាសិកា  សេង.ឃីម

២២. លោក សេង.វ៉ានី  និងអ្នកស្រី ណារិន

២៣. ឧបាសិកា ហេង.ស៊ីវខេង និងម្តាយឈ្មោះ អៀង.ហ្គិច

២៤. លោក យឹម.ស៊ីមុន្នី និងអ្នកស្រី យូ.ប៉ូលីន ព្រមទាំងបុត្រ

២៥. ឧបាសក ឡាយ.សុខុម ឧបាសិកា សួន.ចន្ថា និងបុត្រ

២៦. ឧបាសក ង៉ឹម.ញាណ ឧបាសិកា កាំង.ប៉ូលីន និងបុត្រ

២៧.ឧបាសិកា  អ៊ំ.អ៊ន់

២៨. ឧបាសិកា  ធម្មិកា

២៩. ឧបាសិកា  មូនី.សុខ

៣០. ឧបាសិកា  តាំង.គីមហួ

៣១. ឧបាសក  ស៊ុន.តាំងម៉ាប

៣២. ឧបាសិកា  ប៉ូអាន.ស៊ីវត្ថា

៣៣. ឧបាសិកា  ប៉ូផាវ៉ាណ

៣៤. ឧបាសិកា តឹក.សារឿន ព្រមទាំងកូនចៅទាំងអស់

៣៥. ឧបាសិកា  លីម.ឆេងហ្គិច  ព្រមទាំងបុត្រ

៣៦. ឧបាសិកា សាក់.ស៊ាងអេង

៣៧. ឧបាសិកា  ជា.ផាត  ព្រមទាំងបុត្រ

៣៨. ឧបាសក ប៉ុល.នាង ឧបាសិកា គ្រៀល.ស៊ីយ៉ា និងបុត្រ

៣៩. ឧបាសិកា  គា.ស៊ីន

៤០. ពុទ្ធបរិស័ទ  សុខ.ចាន់រី  និង គៀក.កុម្ភ



Document Produced by deskPDF Unregistered :: http://www.docudesk.com

៤១. ឧបាសិកា  កង. ភឹម

៤២. ឧបាសិកា  អ៊ឹង . ស៊ីវន

៤៣. ឧបាសិកា  រស់ .លីណា

៤៤. ឧបាសិកា  យូ . ណូសណារី

៤៥. ឧបាសកអ៊ុក.សាម៉ាណារ៉ា ឧបាសិកាហ៊ាប.តេង និងបុត្រ

៤៦. ឧបាសក ម៉ៅ.ស្រ៊ុន ឧបាសិកា ទូច.ស៊ីនហ៊ន និងបុត្រ

៤៧. ឧបាសក ពុធ.ប៉ោលាង ឧបាសិកា ហ៊ុន.ស៊ីវអៀង

៤៨.ឆែមសុក្រឹត +ពុធគន្ធា Chhem Sokreth et Puth Kunthea

៤៩. ឧបាសក ម៉ែន.សឿន ឧបាសិកា អៀង.ណារី និងបុត្រ

៥០. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី

៥១. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន



## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ ព្រះពុទ្ធសាសនា ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត~ក្រុង | ពេលផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn<br>-18h00 mn<br>-19h00 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn | -FM 99 MHz<br>-FM 95 MHz<br>-AM 918 MHz<br>-FM 97 MHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn | -FM 92 MHz |
| ខេត្តបាត់ដំបង | -06h00 mn<br>-17h30 mn<br>-20h00 mn | -FM103.2MHz<br>-FM 91 MHz<br>-FM103.2MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5MHz |
| ខេត្តសៀមរាប | -18h30 mn | -FM100.5MHz |
| ខេត្តពោធិសាត់ | -06h00 mn | -FM 98.5MHz |
| ខេត្តកំពត | -18h30 mn | -FM103.5MHz |
| ខេត្តកំពង់ចាម | -05h30 mn | -FM100.5MHz |





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## សៀវភៅដែលរៀបរៀងដោយ

**ខ្ញុំព្រះករុណា ខ្ញុំបាទ**

**✍ ប៊ុត_សាវង្ស ✍**


១_ កូនមាសឪពុក

២_ ជំនួយសតិភាគ ១ ដល់ភាគ៧

៣_ មនុស្សជាមួយនឹងការងារ

៤_ សិក្ខាបទមនុស្សល្អ

៥_ ពរ៤ប្រការ

៦_ ព្រះពុទ្ធភាសិត ៤៣គាថា

៧_ ខ្លឹមសារគួរយល់ដឹង

៨_ ព្រះពុទ្ធសាសនា


**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

ភោគៈទាំងឡាយ តែងសម្លាប់នូវបុគ្គលល្ងង់ខ្លៅ តែមិនសម្លាប់នូវបុគ្គលដែលស្វែងរកត្រើយ គឺព្រះនិព្វានឡើយ ។



## មកដល់កូនសម្លាញ់មាសឪពុក

ឪពុកសូមឱ្យកូន ប្រើប្រាស់ពេលវេលា ឱ្យបាននូវប្រយោជន៍ច្រើនជាទីបំផុត ក្នុងជីវិតរបស់កូន ។

-ពេលទំនេរ សូមឱ្យកូនចាប់សៀវភៅនេះយកមកអាន ហើយចាំទុកនូវសេចក្ដីនីមួយៗផង ។

-ពេលមានទុក្ខ សូមឱ្យកូនពិចារណាតាមការណែនាំរបស់ឪនៅក្នុងសៀវភៅនេះឯង ។

-ពេលនឹកអាល័យ សូមឱ្យកូនអាននូវសៀវភៅនេះដូចជាបាននៅក្បែរម៉ែឪដែរ ។

-ពេលបានសុខ សូមឱ្យកូនចាប់សៀវភៅនេះមករីករាយសប្បាយជាមួយឪពុកម្ដាយ និងមានសេចក្ដីសុខជាមួយក្រុមគ្រួសារដែរ ។

-ពេលកូនមានបញ្ហា សូមឱ្យកូនប្រឹក្សាជាមួយឪពុកម្ដាយ តែបើឪពុកម្ដាយមិននៅទេ សូមឱ្យកូនប្រឹក្សាជាមួយសៀវភៅនេះចុះ ។

ពុកនិងម៉ែ ប្រាថ្នាឱ្យកូនមាននូវសេចក្ដីសុខ ទើបបានជាអប់រំនិងដាស់តឿនក្រើនរំលឹកកូនជារឿយៗ មិនឱ្យកូនលេងហួសពេលវេលា ព្រោះអាចនាំឱ្យកូនមានជំងឺគ្រុនរងាជាដើម ដាស់តឿនកូនមិនឱ្យញ៉ាំនូវអាហារណាដែលមិនល្អ ព្រោះវាអាចនាំឱ្យខូចសុខភាព ហើយបើកូននៅមិនទាន់យល់នូវពាក្យដាស់តឿន ឬក៏មិនស្ដាប់តាមនូវពាក្យទូន្មាន របស់ម៉ែឪទេនោះ ដល់ពេលកូនមិនស្រួលខ្លួនឡើង ឪពុកម្ដាយក៏ត្រូវតែនៅរក្សា និងព្យាបាលកូនយ៉ាងល្អជាទីបំផុតដដែល ។

នៅក្នុងដំណើរជីវិតក៏ដូចគ្នាដែរ ឪពុកម្ដាយបានព្យាយាមអប់រំ និងដាស់តឿនជានិច្ច ឱ្យកូនតាំងចិត្តសិក្សារៀនសូត្រ រៀបចំខ្លួនឱ្យនៅក្នុងសេចក្ដីល្អ មិនឱ្យកូនប្រព្រឹត្តខ្លួនជាមនុស្សឡេះឡោះ តែបើពេលណាដែលកូនប្រព្រឹត្តភ្លាំងភ្លាត់ ដោយហេតុណាមួយនោះ ឪពុកម្ដាយក៏នឹងព្យាយាមជួយកូនយ៉ាងប្ដូរជីវិត ដូចជាពេលដែលកូនមិនស្រួលផ្លូវកាយដូច្នោះឯង ។



ព្រោះហេតុដូចពោលមកនេះ ឪសូមឱ្យកូនមានការចាំជានិច្ចថា ពេលណាដែលកូនមាននូវបញ្ហាកើតឡើង សូមឱ្យកូនប្រឹក្សាជាមួយនឹងម៉ែឪ កុំលាក់លៀមឱ្យសោះ ព្រោះមិនមានអ្នកណាស្មោះត្រង់ និងមានបំណងជួយកូនឱ្យក្រៃលែងជាងម៉ែឪរបស់កូនឡើយ បើម៉ែឪដឹងហើយមិនថាបញ្ហានោះលំបាកលំបិនយ៉ាងណា ម៉ែឪរមែងរួមគ្នាដោះស្រាយ កែខៃបញ្ហាបានគ្រប់រឿងទាំងអស់ ។

កូនមាសឪពុក កាលបើកូនបំពេញតួនាទីដោយសុចរិត ដោយការឆ្លាតវៃ មានសេចក្ដីស្មោះត្រង់ និងកតញ្ញូ កូនរមែងបានទទួលនូវសេចក្ដីរីករាយ ព្រោះរលឹកឃើញអំពើដ៏បរិសុទ្ធរបស់ខ្លួន ហើយកូននឹងបានទទួលនូវផលជាសុខ មានសេចក្ដីចម្រើនដល់អនាគតនៃជីវិតរបស់កូន ព្រមទាំងក្រុមគ្រួសារយ៉ាងពិតប្រាកដ ។

**ឪសូមឱ្យពរដល់កូន ...**

**បាត់ដំបងថ្ងៃ៦កើត ខែស្រាពណ៍ ព.ស.២៥៤៦**

**ពីឪពុករបស់កូន**





Document Produced by deskPDF Unregistered :: http://www.docudesk.com

**បោះពុម្ព ៥០.០០០ ក្បាល**

**សម្រាប់ជាធម្មទាន**



Document Produced by deskPDF Unregistered :: http://www.docudesk.com